**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបការស៊ើបអង្កេតជាក់ស្តែង និង ការស៊ើបអង្កេតបឋម

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក យ៉ាល់ យ៉ា**

សាស្ត្រាចារ្យណែនាំ

**លោក កេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **យ៉ាល់ យ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ជំនាន់ទី ១៩ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច** ។

**សូមលំឱនកាយសម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ**

លោកឪពុក **យ៉េម យ៉ាល់** និងអ្នកម្តាយ **លូង ផេន** ដែលលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើតនិងបានចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងការរស់នៅប្រចាំថ្ងៃទាំងសម្លៀកបំពាក់ ប្រាក់កាស ចំណីអាហារចំពោះខ្ញុំបាទជាកូន និង បានផ្តល់នូវការទូន្មានប្រៀនប្រដៅជាមួយនឹងដំបូន្មានល្អៗប្រកបដោយព្រហ្មវិហារធម៌តាំងពីកូនតូចរហូតដល់ធំដឹងក្តី។ លោកទាំងពីរខិតខំព្យាយាមធ្វើការងាររកកម្រៃយ៉ាងលំបាកមិនថាឆ្លងកាត់នូវឧបសគ្គធំប៉ុណ្ណាក៏លោកទាំងពីរមិនដែលរុញរាឡើយ លោកទាំងពីរតស៊ូជំនះដើម្បីឱ្យកូនៗបានល្អ។ បើគ្មានលោកទាំងពីរទេយើងខ្ញុំក៏គ្មានថ្ងៃនេះដែរ។

ខ្ញុំបាទក៏សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះបងប្រុស បងស្រី និងម្តាយ មីង របស់ខ្ញុំបាទ ដែលពួកគាត់បានជួយជ្រោមជ្រែងផ្តល់ជាកម្លាំងចិត្ត ផ្តល់ជាថវិការ និងផ្តល់ជាទី ស្នាក់អាស្រ័យដល់ខ្ញុំឱ្យបានមករៀនបន្តនៅសាកលវិទ្យាល័យ ប្រសិនបើគ្មានអ្នកទាំងអស់គ្នាទេនោះ ខ្ញុំបាទក៏មិនអាចបានបន្ត ការសិក្សាមកដល់ពេលនេះបានដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះថ្នាក់ដឹកនាំកម្ពុជាដែលលោកបានដឹកនាំប្រទេសប្រកបដោយសុខសន្តិភាព ហើយព្រមទាំងជួយលើកស្ទួយវិស័យអប់រំឱ្យមានភាពល្អប្រសើរ ប្រសិនបើប្រទេសគ្មានសន្តិភាពខ្ញុំបាទក៏មិនបានសិក្សាមកដល់ថ្ងៃនេះដែរ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមសាកលវិទ្យាធិការ និងលោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យទាំងអស់ដែលលោកបានខិតខំបង្ហាត់បង្រៀនដល់ខ្ញុំបាទក៏ដូចជា និស្សិតគ្រប់គ្នា អស់ពីកម្លាំងកាយកម្លាំងចិត្ត ព្រមទាំងអប់រំទូន្មាន ប្រៀនប្រដៅ ដល់រូបខ្ញុំបាទឱ្យក្លាយខ្លួនទៅជា ពលរដ្ឋល្អនៅក្នុងសង្គម ប្រសិនបើគ្មានអ្នកទាំងអស់គ្នាទេខ្ញុំបាទក៏គ្មានថ្ងៃនេះដែរ។ខ្ញុំបាទសូមគោរព និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោកគ្រូសាស្រ្តចារ្យ **កេត សុជាតិ** ដែលលោកបានលះបង់កម្លាំងកាយចិត្តព្រមទាំងពេលវេលាដ៏មានតម្លៃរបស់លោកជួយបង្ហាត់បង្រៀន ផ្តលដំបូន្មានល្អៗ ដើម្បីឱ្យខ្ញុំបាទក្លាយទៅជាសិស្សល្អ ពលរដ្ឋល្អ តាំងពីការបណ្តុះបណ្តាលច្បាប់នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រហូតដល់ពេលនេះ និងធ្វើការណែនាំសារណាមួយនេះតាំងពីដើមរហូតដល់ចប់ ព្រមទាំងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោកគ្រូសាស្រ្តចារ្យ **ហ៊ី សោភា** ដែលបានចែករំលែកនូវចំណេះដឹងលើក្រុមទាំងបួន ដូចជាក្រុម

ព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងជំបូន្មានល្អៗ ព្រមទាំងផ្ដល់នូវបទពិសោធន៍ជាច្រើនវិស័យច្បាប់ប្រកបដោយការណែរនាំ ខ្ញុំបាទជាកូន និងជាសិស្សចងចាំជានិច្ចនៅក្នុងក្រអៅបេះដូង នូវមហាគុណទាំងអស់នេះ ហើយក៏មិនភ្លេចដឹងគុណចំពោះសិស្សច្បងឈិន ដារិត, សិស្សច្បងអៀ ហាំងឡេង, សិស្សច្បងកាន់ វិសាល, សិស្សច្បងរិន វិសាល, សិស្សច្បងឆេង សុផាត និងសិស្សច្បងទាំងអស់ដែលបានចែករំលែកនូវចំណេះដឹងអស់ពីកម្លាំងកាយ ចិត្ត ព្រមទាំងបានចំណាយពេលវេលាផ្ទាល់ខ្លួនដើម្បីចែករំលែកដល់ខ្ញុំ ម្យ៉ាងវិញទៀតក៏អរគុណដល់មិត្តសម្លាញ់ អ៊ូច ច័ន្ទវាសនា និង វណ្ណ សុខនាង ព្រមទាំង ឡៅ គីមលី ដែលបានជួយផ្ដល់នូវមតិយោបល់ និងជួយកែតម្រូវសារណាមួយនេះ។

ជាចុងក្រោយខ្ញុំបាទនឹងតបស្នងសងគុណចំពោះអ្នកមានគុណទាំងពីរ គឺលោកឪពុក អ្នកម្ដាយ និងសាស្ត្រាចារ្យ សិស្សច្បង មិត្តភ័ក្រ្ត ដោយក្ដីគោរព និងស្រឡាញ់ជាទីបំផុត ព្រមទាំងប្រសិទ្ធិពរដល់លោកអ្នកមានគុណទាំងអស់ សូមឱ្យជួបប្រទះតែ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំបាឈ្មោះ **យ៉ាល់ យ៉ា** ជានិស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាន់ទី ១៩ បានឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តអស់រយៈពេល ៤ ឆ្នាំមកហើយ។ មិនថាឆ្លងកាត់ឧបសគ្គ លំបាកយ៉ាងណា ខ្ញុំបាទមិនព្រមបោះបង់ការសិក្សាចោលនោះឡើយ ព្រោះខ្ញុំបាទយល់ថា ការសិក្សាគឺពិតជាសំខាន់ខ្លាំងណាស់ដល់មនុស្សគ្រប់ៗរូបនាពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់ កាលណាយើងមានចំណេះដឹង គឺយើងអាចធ្វើអ្វីៗបានដោយងាយស្រួល ហើយជាពិសេសយើង អាចស្វែងរកការងារបានសមរម្យ មានជីវភាពធូរធារ អាចជួយក្រុមគ្រួសារ ក៏ដូចជាជួយដល់សង្គម ជាតិទាំងមូលផងដែរ។ យ៉ាងណាមិញ មកដល់ពេលនេះខ្ញុំបាទបានខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីស្វែងរកចំណេះដឹង ហើយខ្ញុំក៏បាន និងកំពុងធ្វើការស្រាវជ្រាវសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តនៅឆ្នាំ២០១៩នេះ។ ខ្ញុំបាទពិតជាមានមោទនភាពយ៉ាងខ្លាំងបំផុត ដែលខ្ញុំអាចមានថ្ងៃនេះ ដែលទីបំផុតខ្ញុំអាចទទួលបាននូវលទ្ធផលល្អប្រសើរពីការសិក្សា។

ជាមួយគ្នានេះដែរ ក្នុងចំណោមមុខវិជ្ជាជាច្រើន ដែលខ្ញុំធ្លាប់បានសិក្សាកន្លងមក មុខវិជ្ជាដែលខ្ញុំបាទយកមកសរសេរនោះ គឺទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ។ ខ្ញុំក៏បានជ្រើសរើស យកប្រធានបទមួយគឺ *"ការប្រៀបធៀបការស៊ើបអង្កេតជាក់ស្តែង និង ការស៊ើបអង្កេតបឋម"* មកធ្វើការសិក្សាស្រាវជ្រាវ ។

មូលហេតុ ដែលខ្ញុំបាទសម្រេចជ្រើសរើសយកប្រធានបទមួយនេះមកសិក្សាស្រាវជ្រាវ និងចងក្រងឡើង ព្រោះខ្ញុំបាទចង់ឱ្យនិស្សិតជំនាន់ក្រោយព្រមទាំងសាធារណៈជនឲ្យបានយល់ច្បាស់អំពីចំណុចមួយចំនួនដែល ជាការខុសប្លែកគ្នារវាងដំណើការស៊ើបអង្កេតបទល្មើសជាក់ស្តែងនិងការស៊ើបអង្កេតបឋមក្នុងរឿងក្តីព្រហ្មទណ្ឌ និងដើម្បីទុកជាឯកសារមួយសម្រាប់បំពេញនូវ តម្រូវការរបស់សិស្សប្អូនជំនាន់ក្រោយៗ ដែលមានបំណងចង់ស្រាវជ្រាវបន្តទៅលើអ្វី ដែលទាក់ទង នឹងប្រធានបទនេះ។ ទន្ទឹមនឹងនេះ ខ្ញុំបាទជឿជាក់ថា នៅក្នុងការសរសេរសារណារបស់ខ្ញុំនេះ គឺច្បាស់ជានៅមានភាពខ្វះចន្លោះចៀសមិនរួចឡើយ ទាំងខ្លឹមសារ ក៏ដូចជាកំហុស អក្ខរាវិរុទ្ធ។ ដូច្នេះហើយរាល់កំហុសឆ្គងដែលបានកើតឡើងនេះ ខ្ញុំបាទសុំអភ័យទោសទុកជាមុនពីសំណាក់គណៈកម្មការសាស្រ្តាចារ្យ អស់លោក លោកស្រី និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់។ ខ្ញុំសង្ឃឹមថានឹងទទួលបាននូវការអភ័យទោសពីសំណាក់អ្នកទាំងអស់គ្នា។ ខ្ញុំបាទសូមស្វាគមន៍ទទួលនូវការរិះគន់ ដើម្បីស្តាបនាពី លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ អស់លោក លោកស្រី និងមិត្តអ្នកអានគ្រប់ពេលវេលា។ ជាចុងបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរដល់ លោកគ្រូ អ្នកគ្រូដែលជាគណៈកម្មការ លោកគ្រូសាស្រ្តាចារ្យ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ការស៊ើបអង្កេតជាក់ស្តែង

**ផ្នែកទី១ សញ្ញាណទូទៅ** ........ ៣

**១.១. គោលបំណងនៃការបើកការស៊ើបអង្កេត** ........ ៣

**១.២. ប្រតិបត្តិការទូទៅនៃការស៊ើបអង្កេត** ........ ៤

**ផ្នែកទី២ សមាសភាពនៃអ្នកស៊ើបអង្កេត** ........ ៤

**២.១. ស្ថាប័នអយ្យការ** ........ ៥

២.១.១. សមាសភាពនៃអង្គអយ្យការ ........ ៥

២.១.២. សិទ្ធិ អំណាចរបស់អង្គការអយ្យការ ........ ៥

**២.២.មន្ត្រីនគរបាលយុត្តិធម៌** ........ ៦

២.២.១. រចនាសម្ព័ន្ធនៃមន្ត្រីនគរបាល ........ ៦

២.២.២. នគរបាលយុត្តិធមិរាជធានី - ខេត្ត ........ ៦

២.២.៣. នគរបាលយុត្តិធមិស្រុក-ខណ្ឌ ........ ៧

២.២.៤. មន្ត្រីនគរបាលយុត្តិធមិ ឃុំ - សង្កាត់ ........ ៧

២.២.៥. តួនាទី និងភារកិច្ចរបស់មន្ត្រីយុត្តិធមិ ........ ៧

**ផ្នែកទី៣ លក្ខខណ្ឌករណីបទល្មើសជាក់ស្តែង** ........ ៨

៣.១.១.វិសាលភាពក្នុងការអនុវត្ត ........ ៨

៣.១.២. ការកំណត់ពីបទល្មើជាក់ស្តែង ........ ៩

៣.១.៣. បទល្មើសកំពុងប្រព្រឹត្ត ........ ១០

៣.១.៤. បទល្មើសដែលកំពុងប្រព្រឹត្តរួចភ្លាម ........ ១១

៣.១.៥. ជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញតាម ក្រោមការប្រព្រឹត្តរួមបន្តិចមក ........ ១២

៣.១.៦. ការបន្សល់ទុកនូវតម្រុយលើជនសង្ស័យ ........ ១២

៣.១.៧. ការចាត់ទុកជាបទល្មើសជាក់ស្តែង ........ ១២

**ផ្នែកទី៤ នីតិវិធីពាក់ពន្ធ័នឹងទីកន្លែងកើតហេតុ** ........ ១៣

**៤.១ អត្ថន័យ ទីកន្លែងកើតហេតុ** ........ ១៣

៤.១.២. សកម្មភាពដំបូងនៅកន្លែងកើត ...... ១៤
៣.១.៣. ការត្រួតពិនិត្យទីកន្លែងកើតហេតុ ...... ១៥
៤.១.៤. ការបែងចែកទីកន្លែងកើតហេតុ ...... ១៦
៤.១.៥. ការថែរក្សា និង ការគ្រប់គ្រងភស្តុតាង ឬវត្ថុតាង ......១៧
៤.១.៦. ការធ្វើកំណត់ហេតុពិនិត្យកន្លែងកើតហេតុ ...... ១៩
៤.១.៧. ការគ្រប់គ្រងកំណត់ហេតុ ...... ២០
៤.១.៨. សមាសភាពផ្នែកជំនាញនៃនគរបាលបច្ចេកទេសវិទ្យាសាស្ត្រដែលមានភារកិច្ចប្រមូលភស្តុតាង ...... ២០
**៤.២.ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ......២១
**៤.៣.វិធានការស្រាវជ្រាវ** ......២១
៤.៣.១. វិធានការដំបូង......២២
៤.៣.២. ការចាប់ខ្លួន ......២២
៤.៣.៣.ការឆែកឆេរ ......២២
៤.៣.៤.ការបិទស្លាកបោះត្រាលើវត្ថុតាង ......២៤

## ជំពូកទី២

## ការស៊ើបអង្កេតបឋម

**ផ្នែកទី ១ ការស៊ើបអង្កេតបឋម**......២៥
**១.១.បុព្វហេតុនៃការស៊ើបអង្កេត**......២៥
**១.២. លក្ខណៈទូទៅនៃការស៊ើបអង្កេត** ......២៥
**ផ្នែកទី២ សំណុំរឿង** ......២៥
**២.១ ចំណាត់ការសំណុំរឿង**......២៧
**២.២. កិច្ចស៊ើបអង្កេតបឋម**......២៨
២.២.១ ការចុះទៅកាន់ទីកន្លែងកើតហេតុ ......២៨
២.២.២. ការឆែកឆេរ និងការចាប់យកវត្ថុតាង......២៨
២.២.៣. ការស្តាប់ចម្លើយ ......២៩
២.២.៤. ការពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ......៣០
២.២.៥. ការឃាត់ខ្លួន ......៣០
២.២.៦. ចំពោះការឃាត់ខ្លួនសម្រាប់អនីតិជន ...... ៣២

២.២.៧. ការធានាក្នុងការឃាត់ខ្លួន ..................... ៣២

## ជំពូកទី៣

## ការប្រៀបធៀបស៊ើបអង្កេតជាក់ស្តែង និង ស៊ើបអង្កេតបឋម

**ផ្នែកទី១ ចំណុចដូចគ្នាក្នុងការស៊ើបអង្កេត** ..................... ៣៥

**១.១. បុគ្គលអនុវត្តកិច្ចនីតិវិធី** ..................... ៣៥

**១.២. នីតិវិធីក្នុងការស៊ើបអង្កេត** ..................... ៣៦

១.២.១. បទប្បញ្ញត្តិទូទៅ ..................... ៣៦

១.២.២. បទប្បញ្ញត្តិដោយឡែក ..................... ៣៧

១.២.៣. ការមោឃភាពក្នុងបញ្ញាត្តិទូទៅ ..................... ៣៨

១.២.៤. ការប្រគល់វត្ថុចាប់យក ..................... ៣៩

**ផ្នែកទី២ ចំណុចខុសគ្នានូវវិធាននៃការស៊ើបអង្កេត** ..................... ៤០

**២.១. ការបើកការស៊ើបអង្កេតបឋម និងជាក់ស្តែង** ..................... ៤០

**២.២. ថិរវេលាក្នុងការស៊ើបអង្កេត** ..................... ៤១

**២.៣ ការឆែកឆេរ** ..................... ៤២

**២.៤ បទប្បញ្ញាត្តិស្តីពីមោឃភាពកិច្ចនីតិវិធី** ..................... ៤៣

**សេចក្តីសន្និដ្ឋាន** ..................... ៤៥

**អនុសាសន៍** ..................... ៤៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធចែកចេញជាពីរផ្នែក ៖

ផ្នែកទី ១. ទម្រង់ដីកា និង សេចក្ដីសម្រេចនានារបស់ស្ថាប័នអយ្យការ

ផ្នែកទី ២. ការទទួលបណ្ដឹង និង ការធ្វើកំណត់ហេតុនៅទីកន្លែងកើតហេតុ ព្រមទាំងកាពិនិត្យកត់ហេតុនៅទីកន្លែងកើតហេតុ

# សេចក្តីផ្តើម

ប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នូវសង្រ្គាមរ៉ាំរ៉ៃជាច្រើនលើកច្រើនសារ ជាពិសេសគឺនៅសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុលពត) អស់រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ប្រជាជនរងទុក្ខវេទនាទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយសារមានការបង្ខិតបង្ខំឱ្យធ្វើការហួសកម្លាំង ហូបចុកមិនគ្រប់គ្រាន់ គ្មានសិទ្ធិសេរីភាពពេញលេញ។ មិនតែប៉ុណ្ណោះ នៅក្នុងសម័យនោះ ប្រជាជនជាច្រើនលាននាក់ត្រូវបានស្លាប់បាត់បង់ជីវិត ព្រាត់ប្រាស់គ្រួសារ និងបន្សល់ទុកនូវក្មេងកំព្រា ស្រ្តីមេម៉ាយ ជនពិការព្រមទាំង និស្សិត បញ្ញាវន្តត្រូវបានសម្លាប់ស្ទើរទាំងអស់ ចំណែកឯហេដ្ឋារចនាសម្ព័ន្ធត្រូវបានខ្ទេចខ្ទាំ វត្តអារាមស្ងាត់ជ្រងំ ទីក្រុងទាំងមូលក្លាយជាទីក្រុងគ្មានមនុស្សរស់នៅ ដែលទាំងអស់នេះ គឺជាប្រវត្តិសាស្រ្តដ៏ឈឺចាប់ និងគួរឱ្យរន្ធត់យ៉ាងខ្លាំង។

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាទទួលបានភាពល្អប្រសើររួចផុតពីការកាប់សម្លាប់ និងរួចផុតពីទារុណកម្មយ៉ាងឃោរឃៅ។ ប្រទេសកម្ពុជាចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗរហូតដល់ មានការផ្លាស់ប្តូររបបនយោបាយ ដោយប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស និងបង្កើតឱ្យមានរបបរាជានិយមឡើងវិញ។

នាពេលបច្ចុប្បន្នប្រទេសកម្ពុជា គឺទទួលបាននូវភាពល្អប្រសើរឡើងវិញ មានភាពរីកចម្រើនស្ទើរគ្រប់វិស័យដោយផ្អែកលើឆន្ទៈដ៏មុះមុត ប្តូរផ្តាច់សាមគ្គីភាព និងឯកភាពជាតិក្នុងការកសាងប្រទេសជាតិឱ្យមានការអភិវឌ្ឍ។ ទន្ទឹមនឹងនេះដែរ ប្រជាជនទាំងអស់មានសិទ្ធិសេរីភាពពេញលេញ មានច្បាប់ការពារមិនបណ្តោយឱ្យមានការកាប់សម្លាប់ ឬជិះជាន់សិទ្ធិគ្នាបានទេ។ បុគ្គលគ្រប់រូប គឺមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបាននូវយុត្តិធម៌គ្រប់ៗគ្នា។ ច្បាប់បានកំណត់យ៉ាងច្បាស់ថា គ្មានបុគ្គលណាម្នាក់អាចប្រព្រឹត្តអំពើណាមួយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពរបស់អ្នកដទៃ និងប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គមបានឡើយ។ ប្រសិនបើមានបុគ្គលណាមួយប្រព្រឹត្តអំពើដែលច្បាប់ហាមឃាត់ បុគ្គលនោះនឹងត្រូវទទួលទណ្ឌកម្មទៅតាមប្រភេទ នៃអំពើរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់។ ក៏ប៉ុន្តែ មិនមែនគ្រាន់តែដឹង ឬលឺថាបុគ្គលនោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌភ្លាមសមត្ថកិច្ចអាចចាប់យកបុគ្គលនោះទៅដាក់ទោសនោះទេ ព្រោះថាបុគ្គលគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ ជាធម្មតា កាលណាមានបទល្មើសមួយកើតឡើង ស្ថាប័នមានសមត្ថកិច្ចត្រូវចាប់ផ្តើមធ្វើការស៊ើបអង្កេត ស្វែងរកបទល្មើសយ៉ាងម៉ត់ចត់ទៅតាមការកំណត់របស់ច្បាប់នីតិវិធីព្រហ្មទណ្ឌ។ លើការស៊ើបអង្កេតនេះ និងស្វែងរកអំពីអត្តសញ្ញាណរបស់ជនដែលត្រូវបានគេសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ជាមួយគ្នានេះ ចំពោះការស្រាវជ្រាវលើការប្រៀបធៀបការស៊ើបអង្កេតជាក់ស្តែង និង ការស៊ើបអង្កេតបឋម ខ្ញុំបានធ្វើការបែងចែងជា ៣ជំពូកធំៗ៖ ជំពូកទី១ ការស៊ើបអង្កេតជាក់ស្តែង ជំពូកទី២ ការស៊ើបអង្កេតបឋម និង ជំពូកទី៣ ប្រៀបធៀបការស៊ើបអង្កេតជាក់ស្តែង និង ស៊ើបអង្កេតបឋម។

# ជំពូកទី១
# ការស៊ើបអង្កេតជាក់ស្តែង

## ផ្នែកទី១ សញ្ញាណទូទៅ

ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលដៅសម្រេចអោយបាននូវគោលបំណងច្បាប់ព្រហ្មទណ្ឌ ហើយនីតិវិធីព្រហ្មទណ្ឌបានកំណត់វិធានដែលត្រូវគោរព និងប្រព្រឹត្តតាមយ៉ាងមឹងម៉ាត់ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ[1]។ ប៉ុន្តែ ដើម្បីយកជនណាម្នាក់ទៅដាក់ទណ្ឌកម្មត្រូវតែគោរពតាមគន្លងនៃវិធានដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាចាំបាច់ ពុំដូច្នេះទេកិច្ចនីតិវិធីបានមោឃភាព ដោយសភាស៊ើបសួរជាក់ស្តែងដូចជាដំណើរការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបំពេញបេសកម្មរបស់ខ្លួនដោយគោរពតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌឲ្យបានហ្មត់ចត់ ក្នុងគោលបំណងមិនបំពានសិទ្ធិរបស់ពលរដ្ឋមិនធ្ងន់ធ្ងរពេក។ តាមរយៈបណ្តឹងដែលទទួលបានដោយមន្ត្រីនគរបាលយុត្តិធម៌ពីជនរងគ្រោះធ្វើបណ្តឹងទាមទារ និងពលរដ្ឋដែលឃើញហេតុការណ៍ ព្រមទាំងបណ្តឹងដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់នៅពេលបំពេញបេសកម្មជួបប្រទះនឹងបទល្មើសហើយកសាងសំណុំរឿងបញ្ជូនទៅតុលាការ ម្យ៉ាងវិញទៀតបណ្តឹងត្រូវបានធ្វើដោយដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ក្នុងករណីបណ្តឹងត្រូវបានតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា ដើម្បីជាចំណាត់ការបន្តបន្ទាប់ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដូចជាការបើការស៊ើបសង្កេត ការស៊ើបសួរនិងការជំនុំជម្រះជាដើម។ ចំពោះការស៊ើបអង្កេតត្រូវបានអនុវត្តយន្តការណ៍ពីរផ្សេងគ្នាគឺការស៊ើបអង្កេតបឋម [2] និងជាក់ស្តែង [3] ។តើការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតជាក់ស្តែងមានខុសប្លែកគ្នាយ៉ាងដូចម្តេចខ្លះ?

### ១.១. គោលបំណងនៃការបើកការស៊ើបអង្កេត

ការស៊ើបអង្កត គឺជាកិច្ចនីតិវិធីមួយដែលជាដំណាក់កាលត្រៀម នៃរឿងក្តីព្រហ្មទណ្ឌ ចំពោះកិច្ចនេះត្រូវបានព្រឹត្តទៅមុនពេលចាប់ផ្តើមការចោទប្រកាន់ក្នុងគោលដៅស្វែងរកភស្តុតាង និងដើម្បីកសាងសំណុំរឿងព្រហ្មទណ្ឌ សុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[4]។ ក្នុងគោលបំណងដែលសុំឲ្យយុត្តាធិការទាំងពីរនេះ ធ្វើការវិនិច្ឆ័យសេចក្តីចំពោះជន

[1]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១។
[2] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា១១១ ។
[3] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា៨៥ ។
[4]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា៤ ។

ល្មើសតាមរយៈការចោទប្រកាន់របស់ស្ថាប័នអយ្យការ ដើម្បីស្វែងរកពិរុទ្ធភាពនៃបទល្មើសតាមរយៈការសម្រេចផ្តន្ទាទោស ឬសម្រេចឲ្យរួចខ្លួន។

### ១.២. ប្រតិបត្តិការទូទៅនៃការស៊ើបអង្កេត

នៅក្នុងការបើកប្រតិបត្តិការនៃការស៊ើបអង្កេតនេះ មានគោលដៅចម្បង គឺស្វែងរកភស្តុតាង ពីព្រោះថា នៅពេលចៅក្រមធ្វើការសម្រេចអំពីភាពមានពិរុទ្ធ ឬគ្មានពិរុទ្ធនៃជនល្មើសណាម្នាក់ ចៅក្រមអាចយកភស្តុតាងមកធ្វើការសំអាង ប៉ុន្តែភស្តុតាងមួយចំនួនត្រូវបានបដិសេធចោល ដោយមូលហេតុការទទួលបាននៃភស្តុតាងនោះខុសច្បាប់ ពោលដូចជាភស្តុតាងជាចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបរាងកាយ ឬ ផ្លូវចិត្ត ម្យ៉ាងវិញទៀត ភស្តុតាងក៏ត្រូវបានបដិសេដចោល ឬត្រូវបានធ្វើមោឃភាពនៃកិច្ចនីតិវិធីដូចគ្នាផងដែរ ប្រសិនបើប្រតិបត្តិក្នុងការស៊ើបអង្កេតជាក់ស្តែងមិនគោរពវិធានទាំង១៤ចំណុចដែលបានបញ្ញត្តិមាត្រា១០៥ [5] និងការស៊ើបអង្កេតបឋមមិនគោរពវិធានបញ្ញត្តិមាត្រា១១៧[6]។

មូលដ្ឋានគ្រឹះរបស់ការស៊ើបអង្កេតនេះ គឺភាពបន្ទាន់តម្រូវឲ្យប្រមូលភស្តុតាងដែលនៅមាននៅឡើយរបស់បទល្មើសដែលទើបតែប្រព្រឹត្តថ្មីដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់នេះ នីតិករបានអនុញ្ញាតឲ្យមានវិធានការដែលមានភាពរហ័ស និងការបង្កើតអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះកិច្ចនីតិវិធីស្រាវជ្រាវក្នុងករណីបទល្មើសជាក់ស្តែង។ ករណីនេះ គឺជាការកំណត់កាលពុំអាចឲ្យពេលវេលាណាមួយត្រូវបាត់បង់ពិរុទ្ធជន និងស្លាកស្នាមនៃបទល្មើស ។ រីឯក្នុងវិធានស៊ើបអង្កេតបឋមវិញ គឺជាដំណើរការស្រាវជ្រាវមួយ ដែលជនល្មើសនោះបានប្រព្រឹត្តរួចចប់សព្វគ្រប់ដោយបានបន្សល់ទុកភស្តុតាង ដូចជាឈាម សម្បកគ្រាប់កាំភ្លើង ជាអាទិ៍។

## ផ្នែកទី២ សមាសភាពនៃអ្នកស៊ើបអង្កេត

អង្គការអយ្យការជា ស្ថាប័ននីតិបុគ្គលសារធារណៈមួយដែលបម្រើ និងការពារផលប្រយោជន៍សង្គមរាល់ការរំលោភបំពានមិនត្រឹមត្រូវណាមួយដែលបង្កឲ្យមានចលាចលដល់សង្គម ដោយប៉ះពាល់ដល់សណ្តាប់សាធារណៈ និងសមាជិកសង្គមណាម្នាក់ ព្រមទាំងទ្រព្យសម្បត្តិសាធារណៈទ្រព្យសម្បត្តិឯកជន។ ស្ថាប័នអយ្យការស្ថិតក្នុងក្របខ័ណ្ឌដោយឡែកមួយ ពីព្រោះអង្គអយ្យការមិនធ្វើការជំនុំជម្រះក្តីឡើយ ប៉ុន្តែអយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះ[7] ពោលគឺ ស្ថាប័នអយ្យការជាអ្នកតំណាង

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា១០៥។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា១១៧។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា៥។

ឲ្យសង្គម ។ មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[8] ដែលការធ្វើបណ្តឹងនេះចោទប្រកាន់គ្រប់បុគ្គលទាំងអស់ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិឋានៈសង្គម ឬ ស្ថានភាពឯទៀតឡើយ។ សមាសភាពតួរអង្គមួយទៀតនោះមន្ត្រីនគរបាលយុត្តិធម៌ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ក្រោមការសម្របសម្រួលដោយព្រះរាជអាជ្ញា។

## ២.១. ស្ថាប័នអយ្យការ

តើស្ថាប័នអយ្យការគឺជាអ្វី?

### ២.១.១. សមាសភាពនៃអង្គអយ្យការ

ចំពោះតំណាងអយ្យការអមតុលាការកំពូលរួមមាន៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- និងព្រះរាជអាជ្ញាអមតុលាការកំពូល។

សមាសភាពតំណាងអយ្យការអមសាលាឧទ្ធរណ៍មាដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

សមាសភាពតំណាងអយ្យការអមសាលាដំបូងរួមមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអជ្ញារងអមសាលាដំបូង។

### ២.១.២. សិទ្ធិ អំណាចរបស់អង្គការអយ្យការ

ទូទៅស្ថាប័នអយ្យការមិនអាចអនុវត្តសិទ្ធិអំណាចដោយខ្លួនឯងបានទេ ប៉ុន្តែសិទ្ធិអំណាចទាំងនេះត្រូវបានអនុវត្តដោយអ្នកតំណាងអយ្យការពោលគឺ ដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា-រង និង ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងដែលសិទ្ធិអំណាចទាំងអស់ត្រូវបានផ្តល់ឲ្យដោយបទប្បញ្ញត្តិច្បាប់ជាធរមាន។ ព្រះរាជអាជ្ញាទាំងអស់មានសិទ្ធិជាគោលការណ៍ក្នុងការផ្តើមបណ្តឹងអាជ្ញាចាប់ពីពេលដែលខ្លួនដឹងអំពីបទល្មើស។ ព្រះរាជអាជ្ញាបំពេញដោយខ្លួនឯង ឬ បញ្ជាឲ្យបំពេញគ្រប់កិច្ច

[8] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣, មាត្រា១៣១។

ចាំបាច់ចំពោះការស្វែងរក និងការចោទប្រកាន់បទល្មើស ។ ព្រះរាជអាជ្ញាទទួលបណ្ដឹងតវ៉ា និងបណ្ដឹងបរិហារ ដែលចុះក្នុងបញ្ជីកាន់កាប់ដោយលេខាធិការដ្ឋានរបស់អយ្យការ និង ពិនិត្យវាយតម្លៃចំពោះដំណាក់កាលបន្ទាប់[9]។

## ២.២.មន្ត្រីនគរបាលយុត្តិធម៌

### ២.២.១. រចនាសម្ព័ន្ធនៃមន្ត្រីនគរបាល

រចនាសម្ព័ន្ធរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបែងចែកជាបីថ្នាក់ គឺមន្ត្រីនគរបាលយុត្តិធម៌រាជធានី-ខេត្ត និង មន្ត្រីនគរបាលយុត្តិធម៌ស្រុក-ខណ្ឌ ព្រមទាំងមន្ត្រីនគរយុត្តិធម៌ ឃុំ-សង្កាត់។

### ២.២.២. នគរបាលយុត្តិធម៌រាជធានី - ខេត្ត

រចនសម្ព័ន្ធមន្ត្រីនគរបាលយុត្តិធម៌ខេត្ត-ក្រុងត្រូវបានរួមបញ្ចូលទាំង៖

- ស្នងការ និង ស្នងការរងទទួលបន្ទុកផ្នែកយុត្តិធម៌
- ប្រធាន អនុប្រធានការិយាល័យ និង ប្រធាន អនុប្រធានទទួលបន្ទុកផ្នែកការងារព្រហ្មទណ្ឌចំណុះស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញដែលរួមមាន៖
    - ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល
    - ការិយាល័យនគរបាលសេដ្ឋកិច្ច
    - ការិយាល័យនគបាលបច្ចេកវិទ្យាសាស្ត្រព្រហ្មទណ្ឌ
    - ការិយាល័យប្រឆាំងគ្រឿងញៀន
    - ការិយាល័យប្រឆាំងភេរវកម្ម
    - ការិយាល័យជនបរទេស
    - អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលខណ្ឌ
- ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរណ៍ និងប្រធាន អនុប្រធានផ្នែកនគរបាលចរាចរណ៍( ចំពោះបទល្មើសចរាចរណ៍ )។
- ប្រធាន អនុប្រធាននគរបាលប៉ុស្តិ៍រដ្ឋបាល ចំពោះបទល្មើសព្រហ្មទណ្ឌ។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៥,១០ សីហា ២០០៧,មាត្រា ៥០។

### ២.២.៣. នគរបាលយុត្តិធម៌ស្រុក-ខណ្ឌ

ចំពោះរចនាសម្ពន្ធ័របស់មន្ត្រីនគរបាលយុត្តិធម៌ស្រុក-ខណ្ឌរួមមាន៖

- អធិការ អធីការរងស្រុក-ខណ្ឌ
- នាយការិយាល័យ នាយការិយារងព្រហ្មទណ្ឌកម្រិតធ្ងន់
- នាយការិយាល័យ នាយការិយារងព្រហ្មទណ្ឌកម្រិតស្រាល
- នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន
- នាយការិយាល័យប្រឆាំងគ្រឿងញៀន
- នាយការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- នាយការិយាល័យផ្នែកសេដ្ឋកិច្ច

### ២.២.៤. មន្ត្រីនគរបាលយុត្តិធម៌ ឃុំ - សង្កាត់

រចនាសម្ពន្ធ័របស់មន្ត្រីនគរបាលយុត្តិធម៌ឃុំ-សង្កាត់មានប្រធាន និងអនុប្រធាន ប៉ុស្តិ៍រដ្ឋបាល តាមឃុំ-សង្កាត់។

### ២.២.៥. តួនាទី និងភារកិច្ចរបស់មន្ត្រីយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌មានមុខងារសំខាន់ គឺជានាការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ការបង្ការ និងបង្រ្កាបបទល្មើសអោយមានប្រសិទ្ធភាពខ្ពស់ដើម្បីការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈប្រជាពលរដ្ឋក៏ដូចជាភ្ញៀវជាតិ និង អន្តរជាតិ។ ម្យ៉ាងទៀតគឺជាអ្នកស្វែងរកបទល្មើស[10] ឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទាំងឡាយប្រមូលភស្តុតាងតាមរយៈការបំពេញកិច្ចស៊ើបអង្កេត ហើយបញ្ជូនជនល្មើសទៅសាលាជម្រះក្តីដែលមានភារកិច្ចផ្តន្ទាទោសជននោះ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និយមន័យនៃបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង គឺជាបទល្មើសដែលកំពុងប្រព្រឹត្ត ឬ បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាមៗជាអាទិ៍។ ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែងផងដែរកាលណានៅក្រោយបន្តិចមក ជនដែលសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រផាប់ចាប់ប្រភឹង ឬ បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬ មានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តបទល្មើស។[11]

មូលដ្ឋានគ្រឹះរបស់ការស៊ើបអង្កេតនេះ គឺជាភាពបន្ទាន់ដែលតម្រូវឲ្យប្រមូលភស្តុតាងដែលនៅមាននៅឡើយរបស់បទល្មើសដែលទើបតែប្រព្រឹត្តថ្មី ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់នេះ អ្នក

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៥៦។
[11] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨៦។

តាក់តែងច្បាប់បានអនុញ្ញាតឲ្យមានការបង្កើតវិធានដែលរហ័ស និង ការបង្កើតអំណាចរបស់នគរបាល។ វាគឺជាដំណាក់កាលដែលពុំអាចឲ្យពេលវេលាណាមួយត្រូវបាត់បង់ពិរុទ្ធជន និង ស្លាកស្នាមនៃបទល្មើស។ ហេតុនេះហើយ ទើបគេត្រូវគេត្រូវផ្តល់ឲ្យកម្លាំងសាធារណៈដែលត្រូវប្រឈមមុខនឹងបទល្មើស ដែលឆ្លើយតបមួយលឿន និងមានប្រសិទ្ធភាពដើម្បីជៀសវាងការបាត់បង់ភស្តុតាង និងការគេចខ្លួនរបស់ជនសង្ស័យ ប៉ុន្តែការជ្រើសរើសយកការស៊ើបអង្កេតបែបនេះអាចត្រូវធ្វើ ឬ មិនធ្វើ មានន័យថា នៅចំពោះមុខស្ថានភាពជាក់ស្តែងមន្ត្រីយុត្តិធម៌អាច សម្រេចបើកការស៊ើបអង្កេតតែម្តង [12] ចំណុចនេះត្រូវបានពិចារណា ដោយផ្អែកទៅលើមាត្រា៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលកំណត់ថា ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹម ជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមបទប្បញ្ញត្តិនៃក្រមនេះ។ ក្នុងករណីនេះមានន័យថា ក្នុងស្ថានភាពជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចបើកការស៊ើបអង្កេតជាក់ស្តែង ប៉ុន្តែជាជម្រើសនៃការស៊ើបអង្កេតនេះត្រូវបានធ្វើឡើងដោយផ្អែកទៅលើកាលៈទេសៈនៃបទល្មើស និងផលពិបាកនៃដែលអាចព្រាងទុកមុនក្នុងការស្វែងរកអ្នកប្រព្រឹត្ត ឬ ប្រមូលភស្តុតាង។ ដោយសារតែអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌កាន់តែកើនឡើងៗ នៅពេលធ្វើការស៊ើបអង្កេតជាក់ស្តែងទើបការបើកការស៊ើបអង្កេតបែបនេះត្រូវបានតាក់តែងដោយយ៉ាងតឹងរ៉ឹងបំផុត។[13]

## ផ្នែកទី៣ លក្ខខណ្ឌករណីបទល្មើសជាក់ស្តែង

### ៣.១.១. វិសាលភាពក្នុងការអនុវត្ត

ក្នុងដំណើរការនៃការបើកការស៊ើបអង្កេតជាក់ស្តែងនេះ អាចធ្វើទៅបានតែក្នុងករណីដែលបទល្មើសគេសង្ស័យនោះជាបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង។ ដូច្នេះផងដែរ ក៏ត្រូវបានបដិសេដក្នុងការបើកការស៊ើបអង្កេតបែបនេះចំពោះបទលហុ។ ដោយសារតែមូលហេតុនៃភាពទូលំទូលាយរបស់អត្ថបទឯកសារច្បាប់ ក៏ត្រូវបានបដិសេដផងដែរនូវ បទមជ្ឈិម ដែលត្រូវផ្តន្ទាទោស ដោយការពិន័យប្រាក់ជា។ គេត្រូវចាត់ទុកថាទ្រង់ទ្រាយខាងក្រៅមានតម្លៃស្មើនឹងជាការពិត ហើយទោះបីជាក្រោយបទល្មើសនោះមានលក្ខណៈមិនសូវធ្ងន់ធ្ងរ ដែលមន្ត្រីនគរបាលយុត្តិធម៌អាចជឿបានដោយត្រឹមត្រូវក៏ដោយ។ ឧទាហរណ៍ បទហិង្សាដោយចេតនាលើអ្នកដទៃ អាចមើលទៅឃើញថាត្រឹមតែបទលហុធម្មតាក្នុងករណីហិង្សាស្រាល ។ ជាការពិតណាស់នៅក្នុងមាត្រា១១៧ នៃក្រមព្រហ្មទណ្ឌបានចែងថា អំពើហឹង្សារដោយចេតនា លើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី (មួយ)ឆ្នាំ ទៅ ៣

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨៥

[13] សៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់ឯកឧត្តម ហ៊ី សោភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទំព័រ១៥

(បី)ឆ្នាំ និងពិន័យប្រាក់ពី២០០០០០០(ពីរលាន)រៀល ទៅ៦០០០០០០(ប្រាំមួយ)រៀល ។ មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌអំពើប្រព្រឹត្តលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឲ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។ មាត្រា ២២៨ ចែងថា បើអំពើប្រព្រឹត្តលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឲ្យដទៃមានរបួសទេនោះមាន ព្យសនកម្មស្រាលវាគឺ ជាបទលហុ ដែលពិន័យត្រឹមតែជាប្រាក់ពី ៥០០០ (ប្រាំពាន់) រៀល ដល់ ១០០.០០០ (មួយសែន) រៀល ។

ការបើកស៊ើបអង្កេតបែបនេះក៏អាចធ្វើទៅបានផងដែរ ក្នុងករណីប្រព្រឹត្តបទឧក្រិដ្ឋ ឬបទ មជ្ឈិមដែលផ្តន្ទាទោសដាក់ពន្ធនាគារនៅពេលដែលការប៉ុនប៉ងនេះត្រូវបានបង្ក្រាបឲ្យច្បាស់លាស់ ដោយច្បាប់ ។ អ្នកដែលមានសមត្ថកិច្ចក្នុងការដឹកនាំការស៊ើបអង្កេតបែបនេះគឺ ព្រះរាជអាជ្ញា និង មន្ត្រីនគរបាលយុត្តិធម៌។ ភ្នាក់ងារនគរបាលយុត្តិធម៌ មានអំណាចផ្ទាល់ដោយត្រឹមតែពិនិត្យកត់ត្រា បទឧក្រិដ្ឋ មជ្ឈិមជាក់ស្តែងក្នុងកំណត់ហេតុប៉ុណ្ណោះ។ ចំពោះកិច្ចស៊ើបអង្កេតភ្នាក់ងារមន្ត្រីនគរបាល ជួយមន្ត្រីនគរបាលយុត្តិធម៌ឬ បំពេញកិច្ចទាំងនេះក្រោមការត្រួតពិនិត្យរបស់នគរបាលយុត្តិធម៌។ គួរ កត់ចំណាំដែរថា ក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង បុគ្គលគ្រប់រូបអាចចាប់ខ្លួន ជនល្មើស និងនាំខ្លួនជននោះ ហើយប្រគល់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ដែលស្ថិតនៅជិតយើងបំផុត[14]។

### ៣.១.២. ការកំណត់ពីបទល្មើជាក់ស្តែង

ដើម្បីបើកការស៊ើបអង្កេតជាក់ស្តែងបាន គឺដាច់ខាតត្រូវតែកំណត់អំពីស្ថានភាពជាក់ស្តែង ជាមុនសិន។ ការកំណត់លក្ខណៈជាក់ស្តែងគឺ សំខាន់បំផុតពីព្រោះថាស្ថានភាពនេះហើយដែល តម្រូវឲ្យមានការបង្កើតការស៊ើបអង្កេតបែបនេះ។ ដោយការស៊ើបអង្កេតនេះជាសមត្ថកិច្ចរបស់មន្ត្រី នគរបាល ក៏ដូចជាភ្នាក់ងារនគរបាយុត្តិធម៌ ដែលស្ថិតក្រោមការត្រួតពិនិត្យដោយអំណាចតុលាការ ក្នុងការវាយតំលៃជាបឋមអំពីអាទិភាពនៃលក្ខណៈជាក់ស្តែង មុននឹងអនុវត្តអំណាចបង្ខំរបស់ខ្លួន ឬ មុនបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង បើពុំដូច្នេះទេនោះ មន្ត្រីនិងភ្នាក់ងារនគរបាលនឹងទទួល ទោសព្រហ្មទណ្ឌ ទោសវិន័យ និងទោសរដ្ឋប្បវេណីព្រមទាំងជំបូងបំផុតនោះគឺ ត្រូវមោឃភាពនៃ កិច្ចដែលបានបំពេញ។ ការពិនិត្យវិនិច្ឆ័យនេះ ធ្វើឡើងដោយយោងទៅលើភាពជាក់ស្តែងដែល រៀបរាប់ដោយអ្នកតាក់តែងច្បាប់ដូចដែលមានចែងក្នុងមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង អាចធ្វើបានតែករណីដែលរកឃើញថា ស្ថានភាពជាក់ស្តែង ដែលច្បាប់បានកំណត់ជាមុនពិតជាមានយ៉ាងប្រត្យក្ស។ ស្ថានភាពជាក់ស្តែងនេះ ត្រូវបានពិនិត្យ

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា៨៧

វាយតំលៃក្នុងពេលអន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិ។ បើពុំមានស្ថានភាពជាក់ស្តែងដែលបានកំណត់ជាមុនទេ ភ្នាក់ងារដែលបើកការស៊ើបអង្កេតបែបនេះនឹងគ្មានសមត្ថកិច្ច ហើយគ្រប់កិច្ចដែលខ្លួនបានបំពេញនិងត្រូវបានចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ។ ដើម្បីទទួលបាននូវតម្រុយពីខាងក្រៅដែលបានកំណត់ស្ថានភាពជាក់ស្តែងដែលមន្ត្រីនគរបាលយុត្តិធម៌ មានការសង្ស័យដោយសារមានបណ្តឹងបរិហារជាដើមនោះ មន្ត្រីនេះអាចបើកជាមុននូវការស៊ើបអង្កេតបឋមដើម្បីឈានដល់ការរកឃើញតម្រុយដែលអាចឲ្យខ្លួនសន្មត់បានពីលក្ខណៈជាក់ស្តែង ។ ពេលដែលការស៊ើបអង្កេតបឋមត្រូវបានបញ្ចប់ អ្នកស៊ើបអង្កេតអាចបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ហើយប្រើប្រាស់អំណាចបង្ខំដែលកើតចេញពីការស៊ើបអង្កេតនេះ បើករណីដែលខ្លួនបានប្រមូលតម្រុយខាងក្រៅដែលអនុញ្ញាតឲ្យមានការកំណត់ពីស្ថានភាពជាក់ស្តែង ដោយផ្អែកលើភាពជាក់ស្តែង ដែលមានចែងក្នុងមាត្រា៨៦ និង មាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ឧទាហរណ៍: ការឃ្លាំមើលជនទុច្ចរិតអាចអនុញ្ញាតឲ្យរកឃើញតម្រុយភស្តុតាងវត្ថុដែលកំណត់នៅភាពជាក់ស្តែងនៃអំពើលួច ព្រមទាំងការរកឃើញក្នុងពេលកំពុងឆែកឆេរ ដែលធ្វើឡើងក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម លើការជួញដូរគ្រឿងញៀន។ ក៏ដូចគ្នានេះដែរស្ថានភាពជាក់ស្តែង អាចត្រូវបានរកឃើញក្នុងពេលបំពេញកិច្ចស្រាវជ្រាវ ដើម្បីស្វែងរកបទល្មើសមួយផ្សេងទៀត ក្នុងក្របខណ្ឌការស៊ើបអង្កេតបឋម និង ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ព្រមទាំងការស៊ើបសួរដែលស្ថិតនៅក្រោមយុត្តាធិការរបស់ចៅក្រមស៊ើប។ ឧទាហរណ៍: នៅពេលដែលអន្តរាគមន៍ ដោយស្របច្បាប់ក្នុងផ្ទះ នគរបាលបានសម្គាល់ថាមានវត្ថុដែលដូចគ្នា និងវត្ថុដែលទើបត្រូវបានលួច ក្នុងពេលមានអំពើលួចដោយប្រើប្រាស់ហិង្សា និងក្នុងពេលពិនិត្យកំណត់ត្រា គ្រោះថ្នាក់ចរាចរណ៍ ដែលប៉ះពាល់ដល់ រូបរាងកាយ ឬ សម្ភារៈ ភ្នាក់ងារនគរបាល រកឃើញអាវុធជាតិផ្ទុះក្នុងរថយន្តជាអាទិ៍។ បន្ទាប់មកភ្នាក់ងារប្រគល់អាវុធនេះ ទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលបានទទួលពាក្យបណ្តឹងតាមរយៈកំណត់ហេតុ និង បានបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ទៅលើការដឹកជញ្ជូនអាវុធដោយខុសច្បាប់ ។

ម្យ៉ាងវិញទៀតត្រូវបានចាត់ទុកជាស្ថានភាពជាក់ស្តែងផងដែរក្នុងករណីដូចខាងក្រោម៖

### ៣.១.៣. បទល្មើសកំពុងប្រព្រឹត្ត

ក្នុងស្ថានភាពត្រូវបានចាត់ទុកថាបទល្មើសដែលកំពុងប្រព្រឹត្តគឺ ជាករណីនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលកំពុងតែប្រព្រឹត្តទៅដោយឥតដាច់បន្តរប្រព្រឹត្តជាក់ស្តែង ចំពោះមុខព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ជាអាទិ៍។ មួយវិញទៀត ស្ថានភាពជាក់ស្តែងដូចជា ចារីត្រូវបានគេឃើញទាន់ក្នុងអំពើសកម្ម ឬ អកម្ម ចំពោះការប្រព្រឹត្តអាចត្រូវបានគេឃើញដោយផ្ទាល់។ ឧទាហរណ៍ ក្នុងករណីដែលបុគ្គលម្នាក់ ត្រូវបានគេឃើញថាកំពុងបន្លំយករបស់អ្នកដ៏ទៃ។ ដូច្នេះ វាជាភាពជាក់ស្តែង

ពិតប្រាកដ (នគរបាល បានឃើញដោយផ្ទាល់នូវការប្រព្រឹត្តអំពើដែលច្បាប់ចាត់ទុកជាបទល្មើស) ដែលអនុញ្ញាតអោយបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែងភ្លាមៗ ដែលជាទូទៅត្រូវបានកំណត់ដោយការចាត់បានចារី។ក៏ប៉ុន្តែការប្រព្រឹត្តក៏ត្រូវបានមើលឃើញតាមរយៈការទទួលបាននូវតម្រុយដែលបញ្ជាក់ថា វាទំនងជាពិត។ មានបទល្មើសជាច្រើនទៀតដែលកំពុងត្រូវបានប្រព្រឹត្ត ប៉ុន្តែមិនបង្ហាញឲ្យឃើញផ្ទាល់។ ឧទាហរណ៍: ការកាន់កាប់អាវុធដែលត្រូវបានហាមឃាត់ ការកាន់កាប់គ្រឿងញៀនជាដើម។ ស្ថានភាពជាក់ស្តែងអាចនឹងត្រូវបានកំណត់ ហើយការស៊ើបអង្កេតបទល្មើសជាក់ស្តែង អាចនឹងត្រូវបើក លុះត្រាតែមានតម្រុយខាងក្រៅនៃអាកប្បកិរិយាទុច្ចរិត។ ការទទួលបានតម្រុយ ទាំងនេះត្រូវតែធ្វើឡើងតាមគន្លងច្បាប់។ ទាក់ទងនឹងបទល្មើសលាក់បាំង ដូចជាបទល្មើសដែលកើតឡើងកន្លែងបិទជិតដែលមន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចចូលបាន ហើយដែលការទទួលបានតម្រុយមិនអាចធ្វើទៅកើត។ ឧទាហរណ៍: កន្លែងពិសោធន៍ ឬកន្លែងផលិតគ្រឿងញៀនគេត្រូវធ្វើការស៊ើបអង្កេតបឋមជាមុន ដើម្បីអាចរកឃើញតម្រុយជាវត្ថុ ដែលអនុញ្ញាតឲ្យបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬបើកការស៊ើបសួរ។ ក្នុងករណី ការជួញដូរគ្រឿងញៀន បន្ទាប់ពីទទួលបានភស្តុតាងជាក់ស្តែងពីសកម្មភាពទុច្ចរិត ដោយមានជំនួយពីការតាមដាន មន្ត្រីនគរបាលយុត្តិធម៌អាចបើកការឆែកឆេរមន្ទីរពិសោធន៍ជាក់លាក់ ក្នុងក្របខណ្ឌការស៊ើបអង្កេតជាក់ស្តែង។ ហេតុដូច្នេះបើពុំមានតម្រុយពីខាងក្រៅ ការសង្ស័យ និងការបរិហារអាណាមិកមិនចូលក្នុងលក្ខខណ្ឌដែលទាមទារ[15]។ ផ្ទុយទៅវិញ បណ្តឹងបរិហាររបស់ជនរងគ្រោះអាចចាត់ទុកជាភស្តុតាងជាក់ស្តែងបាន ។

### ៣.១.៤. បទល្មើសដែលកំពុងប្រព្រឹត្តរួចភ្លាម

មានន័យថាក្រោយពីការប្រព្រឹត្តទើបបញ្ចប់ ភ្លាមត្រូវបានបកស្រាយទៅលើការយល់ឃើញរបស់សង្គមតាមរយៈការវាយតម្លៃដោយចៅក្រម។ ជាការលំបាកបិត ត្រង់ថានៅក្នុងក្រមបានបញ្ចូលសញ្ញាណនៃថេរវេលារវាងការប្រព្រឹត្តបទល្មើស និងការរកឃើញការប្រព្រឹត្តដោយពុំត្រូវបានបញ្ជាក់ពីរយៈពេលឲ្យច្បាស់លាស់ឡើយ។ ដូច្នេះរយៈពេលអាចត្រូវបានកំណត់ត្រឹម ២៤ម៉ោង ដែលជាការសមរម្យមួយរបស់ពលរដ្ឋនៅក្នុងសង្គមផ្ទាល់។ ជាការពិតណាស់ ចំណុចនេះនឹងត្រូវបញ្ជាក់ដោយតុលាការកំពូល ដើម្បីមានយន្តការណ៍ច្បាស់លាស់មួយ ក្នុងកិច្ចស៊ើបអង្កេតបទល្មើសជាក់ស្តែង។ បណ្តឹង ឬ ការពិនិត្យកត់ត្រាគួរតែធ្វើឡើងក្នុងរយៈពេលមួយដែលនៅជិតការប្រព្រឹត្តបំផុត ដើម្បីកុំឲ្យបាត់លក្ខណៈបច្ចុប្បន្ន ឬ ភាពនៅថ្មីៗនៃការប្រព្រឹត្តទៅចំពោះបទល្មើសជាក់ស្តែង

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨៦

ដែលទើបប្រព្រឹត្តរួចភ្លាម ។ ឧទាហរណ៍: មានគេឃើញជនសង្ស័យនៅកន្លែងប្រព្រឹត្តក្រោយពីការប្រព្រឹត្តរួចបន្តិចមក។

**៣.១.៥. ជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញតាម ក្រោមការប្រព្រឹត្តរួចបន្តិចមក**

ការស្រែកប្រកូកប្រកាស ជាសាធារណៈជនអាចឲ្យនិយមន័យបានថា ជាការស្រែកដេញប្រកិត ដោយមានការចង្អុលបង្ហាញភ្លាមៗដែលបុគ្គលម្នាក់ថា ជាអ្នកប្រព្រឹត្តអំពើដែលប៉ះពាល់ដល់សណ្តាប់សាធារណៈ។ ដូច្នេះការស្រែកប្រកូកប្រកាសជាសាធារណៈនេះ ខុសពីពាក្យចចាមរាម ឬពាក្យបរិហារកេរ្តិ៍។ ការស្រែកប្រកូកប្រកាសជាសាធារណៈ ត្រូវធ្វើឡើងក្នុងរយៈពេលមួយដែលនៅជិតការប្រព្រឹត្តបំផុត។ យើងសង្កេតឃើញថា លក្ខខណ្ឌរយៈពេលនេះក៏មិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ ដោយអ្នកតាក់តែងច្បាប់ដែរ ហេតុដូច្នេះ វាត្រូវទុកឲ្យចៅក្រមពិចារណា វាយតម្លៃដោយឯករាជ្យ ។

**៣.១.៦. ការបន្សល់ទុកនូវតម្រុយលើជនសង្ស័យ**

ជនសង្ស័យត្រូវបានគេឃើញក្រោយការប្រព្រឹត្តបន្តិចថាមានកាន់កាប់វត្ថុ ឬតម្រុយផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាជននេះ បានប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ណាមួយ ។ នេះជាករណីដែលបុគ្គលម្នាក់ត្រូវបានកត់សម្គាល់ពីការប្រព្រឹត្តបទល្មើសថ្មីៗ តាមរយៈការរកឃើញវត្ថុ ឬតម្រុយផ្សេងៗ។ ដូចជា ស្នាមឈាមជាដើម ដែលស្ថានភាពជាក់ស្តែងបែបនេះអាចត្រូវបានស្តែងចេញក្នុងករណីដែលកំពុងតែមានការត្រួតពិនិត្យចរាចរណ៍ នគរបាលពិនិត្យឃើញថាមានក្លិនអាភៀន ក្លិនរំសេវ ឬ ស្នាមឈាម ដែលជាប់ក្នុងឡាន និង ចេញពីឡាន។

**៣.១.៧. ការចាត់ទុកជាបទល្មើសជាក់ស្តែង**

បន្ថែមលើករណីដែលមានកំណត់ក្នុងនិយមន័យ បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែលមានចែងក្នុងមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឲ្យមានការស៊ើបអង្កេតបទល្មើសជាក់ស្តែងទោះបីជាពុំបានស្ថិតក្នុងស្ថានភាពមួយក្នុងចំណោមស្ថានភាពទាំង៥ នៃកថាខណ្ឌខាងលើក៏ដោយ។ ជាការពិតណាស់ការស៊ើបអង្កេតបទល្មើសជាក់ស្តែងអាចត្រូវបានបើកគ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិម បើបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្នុងកន្លែងដែលអ្នកកាន់កាប់សុំអោយព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌មកពិនិត្យ។ ប្រសិនបើគ្មានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ទេ ភ្នាក់ងារនគរបាលយុត្តិធម៌អាចចូលអន្តរាគមន៍ និងពិនិត្យកត់ត្រាអំពីព្រឹត្តិហេតុដែលកើតឡើងនៅកន្លែងកើតហេតុនោះបាន។ យន្តការណ៍បន្ទាប់ពីចុះអន្តរាគមន៍ពិនិត្យកត់ត្រាភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវផ្តល់ដំណឹងភ្លាមដល់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឲ្យមន្ត្រីនេះបំពេញបេសកកម្មរបស់ខ្លួន។ បិត

នៅក្នុងស្ថានភាពនេះ សំដៅដល់ការស្រែកហៅរបស់ម្ចាស់ផ្ទះឲ្យនគរបាល ឬកងរាជអាវុធហត្ថចូលមកពិនិត្យបទល្មើសព្រហ្មទណ្ឌ ដែលគេពុំដឹងថាជាបទល្មើសជាក់ស្តែង ឬមិនមែន។ ឧទាហរណ៍: ដូចជាការលួចដោយមានការទម្លាយសោរ ដែលកម្មសិទ្ធិករ ឬអ្នកកាន់កាប់ផ្ទះ បានឃើញនៅពេលត្រឡប់មកដល់ផ្ទះ ដោយសភាពខាងក្នុងមានភាពរញ៉េរញ៉ៃហាក់បីស្វែងរកវត្ថុមានតម្លៃដូចជាការដែលគាស់ទូរើសសម្លៀកបំពាក់ដែលការប្រព្រឹត្ត និង ការបន្សល់ទុកនៅភស្តុតាងដែលគ្មានអ្នកដឹង។ ការលួចនេះអាចត្រូវប្រព្រឹត្តច្រើនថ្ងៃមុនការពិនិត្យឃើញ ប៉ុន្តែការស្នើសុំរបស់ម្ចាស់ផ្ទះមានអានុភាពប្រគល់អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងអោយទៅមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកទទួលបណ្តឹងដោយផ្ទាល់ ឬតាមរយៈព្រះរាជអជ្ញាក្នុងករណីដែលព្រះរាជអជ្ញាជាអ្នកដែលបានស្នើរសុំ។ ក្នុងស្ថានភាពជាក់ស្តែងនឹងត្រូវពិនិត្យកត់ត្រាតាមរយៈតម្រុយជាវត្ថុខាងក្រៅមួយ ឬច្រើន ដែលនាំឲ្យគេអាចសន្និដ្ឋានអំពីអាទិភាពនៃភាពជាក់ស្តែងរបស់វា។ មន្ត្រីនគរបាលយុត្តិធម៌ភ្នាក់ងារនគរបាលយុត្តិធម៌ និងប្រមូលភស្តុតាង ដែលអាចឲ្យខ្លួនគិតថាជាបទឧក្រិដ្ឋ ឬមជ្ឈិមកំពុងតែប្រព្រឹត្ត ឬទើបតែប្រព្រឹត្តរួច។ ស្ថានភាពជាក់ស្តែងមិនតម្រូវឲ្យមានភាពប្រាកដជាក់លាក់នៃបទល្មើស និងការចោទប្រកាន់ទៅលើបុគ្គលណាម្នាក់ជាកំណត់នោះទេ ពីព្រោះកាស៊ើបអង្កេតមានកម្មវត្ថុជាក់លាក់មួយគឺ ការបង្ហាញឃើញឲ្យច្បាស់លាស់ ឬការបដិសេធចោលនៅស្ថានភាពជាក់ស្តែងនេះទេ ក៏ប៉ុន្តែស្ថានភាពជាក់ស្តែងតម្រូវឲ្យមានតម្រុយជាសត្យានុម័តច្បាស់លាស់ដែលយើងអាចកំណត់បានជាធាតុនៃអំពើដែលពុំមែនត្រឹមតែជាការសង្ស័យធម្មតា របស់នគរបាលផ្ទុយទៅវិញត្រូវតែមើលឃើញជាក់ស្តែងពីខាងក្រៅ ហើយដែលធ្វើអោយការប្រព្រឹត្តនាពេលបច្ចុប្បន្ន ឬ ដំណើរការក្នុងការប្រព្រឹត្តទៅនៃបទល្មើសមើលទៅទំនងជាពិតប្រាកដ។

## ផ្នែកទី៤ នីតិវិធីពាក់ពន្ធ័នឹងទីកន្លែងកើតហេតុ

### ៤.១ អត្ថន័យ ទីកន្លែងកើតហេតុ

ទីកន្លែងកើតហេតុមួយ គឺជាកន្លែងនៅក្នុងទីជិតខាងផ្ទាល់នៃហេតុដែលកើតឡើងដែលនៅម្តុំទីនោះគេអាចនឹងប្រទះឃើញនូវភស្តុតាងនានា។ ត្រូវចងចាំថាមានការកើតហេតុជាច្រើនដែលកើតឡើងបន្ទាប់បន្សំ ឬក៏បន្ទាប់ពីបទល្មើសជាក់ស្តែង ហើយក៏មានការកើតហេតុជាច្រើនដែលកើតឡើងមុនពេល ឬនៅពេលរៀបចំគម្រោងប្រព្រឹត្តបទល្មើស។ ចាំបាច់ត្រូវកំណត់យកគ្រប់ទីកន្លែងទាំងអស់ដែលមានធាតុផ្សំនៃបទល្មើសដែលត្រូវបានគេប្រព្រឹត្ត។ ឧទាហរណ៍: ក្នុងករណីមានការប្រព្រឹត្តបទប្លន់ប្រដាប់អាវុធនៅទីជិតខាងផ្ទាល់នៃអំពើប្លន់នោះ (ដូចជា កន្លែងលក់ទំនិញច្រកសម្រាប់ដើរ។ល។ត្រូវបានចាតទុកជាកន្លែងកើតហេតុដំបូង។

ក្នុងករណីជនល្មើសធ្វើដំណើរចេញបន្ទាប់ពីអំពើប្លន់ ហើយរាប់ប្រាក់ ឬក៏លាក់កាំភ្លើងទុក នោះត្រូវចាត់ទុកជាកន្លែងកើតហេតុបន្ទាប់។

### ៤.១.២. សកម្មភាពដំបូងនៅកន្លែងកើត

នៅក្នុងករណី ដែលអាចធ្វើបាននគរបាលដែលមានវត្តមាននៅកន្លែងកើតហេតុមុនគេបង្អស់ត្រូវៈ

- ធ្វើការសង្គ្រោះបន្ទាន់ចំពោះជនរងគ្រោះ
- ពិនិត្យឲ្យច្បាស់ តើមានការប្រព្រឹត្តបទល្មើសមែនដែរឬទេ?
- បំបែកជនល្មើសចេញ ឆែកឆេរ និងរក្សាសុវត្ថិភាពជនល្មើស
- កំណត់ទំហំនៃកន្លែងកើតហេតុ
- ចាត់វិធានការណ៍ ការពារភស្តុតាងសំខាន់ចាំបាច់ជាពិសេសបើសិនភស្តុតាងទាំងនោះអាចនឹងត្រូវខូចបាត់បង់មុនពេលដែល បុគ្គលិកនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកទេសមកដល់។
- ដៅសម្គាល់ព្រំដែននៃកន្លែងកើតហេតុ ដោយប្រើខ្សែ ឬ ដោយប្រើសម្ភារៈណាមួយក៏បានដែលអាចនឹងបង្ហាញច្បាស់ពីបរិវេណហាមមិនឲ្យអ្នកគ្មានភារៈកិច្ចចូល។
- កំណត់ចំណុចច្រកចេញចូលនៃកន្លែងកើតហេតុ
- ឲ្យប្រជាជនចាកចេញពីកន្លែងកើតហេតុ
- ផ្តើមធ្វើកំណត់ហេតុការពារកន្លែងកើតហេតុ
- ថតរូបកន្លែងកើតហេតុ
- ធ្វើការកត់ត្រា និងគូសប្លង់ព្រាង ស្លាកស្នាម វត្ថុតាង នៃកន្លែងកើតហេតុ
- ព្យាយាមស្វែងរក និងរក្សាទុកសាក្សីឲ្យនៅដោយឡែកកត់ត្រាសេចក្តីរាយការណ៍របស់សាក្សីឲ្យបានពិស្តារ និងសំណូមពរសាក្សីឲ្យនៅទីនោះសិន។
- ការពារមិនឲ្យមនុស្សចេញចូលកន្លែងកើតហេតុ ដោយរាប់បញ្ចូលនៃនគរបាល ឬសមត្ថកិច្ចផ្សេងទៀតដែលគ្មានភារកិច្ចចាំបាច់ដែលមិនមែនជាមុខងាររបស់ខ្លួននៅទីនោះ។

### ៣.១.៣. ការត្រួតពិនិត្យទីកន្លែងកើតហេតុ

កាលបើត្រូវបានស្នើសុំឲ្យចូលរួមនៅកន្លែងកើតហេតុនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ដែលមានវត្តមានមុនគេបង្អស់ត្រូវចាត់ការគ្រប់គ្រងកន្លែងកើតហេតុត្រូវគេហៅក្នុងតួនាទីជា "អ្នកគ្រប់គ្រងកន្លែងកើតហេតុ"។ នគរបាលផ្នែកបច្ចេកទេសវិទ្យសាស្ត្រម្នាក់ត្រូវស្ថិតនៅចាត់ការ

គ្រប់គ្រងទីកន្លែងកើតហេតុ និងការធ្វើកោសល្យវិច្ច័យការគ្រប់គ្រងត្រួតពិនិត្យអាចនឹងត្រូវប្រគល់ឲ្យអ្នកឯកទេសផ្សេងទៀត អាស្រ័យទៅលើប្រភេទលក្ខណឧបទ្វរហេតុនេះ។ ត្រូវជូនដំណឹងទៅនគរបាលដែលមានភារកិច្ចស៊ើបអង្កេតអំពីការផ្លាស់ប្តូរការគ្រប់គ្រងនេះ។

ចំពោះអ្នកគ្រប់គ្រងកន្លែងកើតហេតុមានភារកិច្ចដូចខាងក្រោមៈ

- ទទួលខុសត្រូវលើការស្នើសុំ ឲ្យបណ្តាផ្នែកផ្សេងៗរបស់នគរបាលបច្ចេកទេសវិទ្យាសាស្ត្រចូលរួម
- ជូនពតិមាននឹងអញ្ជើញព្រះរាជអាជ្ញា និង អង្គភាពពាក់ព័ន្ធពិភាក្សា ឬ បង្កើតគណៈកម្មាធិការដើម្បីត្រួតពិនិត្យ ទីកន្លែងកើតហេតុ
- ដឹកនាំសកម្មភាពជំនាញបច្ចេកទេសវិទ្យាសាស្ត្រ យោងទៅតាមសកម្មភាពជាក់ស្តែងនៅទីកន្លែងកើតហេតុ
- គ្រប់គ្រងរក្សាទីកន្លែងកើតហេតុរហូតដល់ពេលដែលបណ្តាផ្នែកបានបញ្ចប់ការធ្វើកោសល្យវិច្ច័យ
- មានសិទ្ធហាមមិនឲ្យជនណាចូលទីកន្លែងកើតហេតុក្រៅពីជនពាក់ព័ន្ធ ដើម្បីការពារមិនឲ្យមានការប៉ះពាល់ខូចខាតដល់កន្លែងកើតហេតុ
- ត្រូវអនុវត្ត ឬ ត្រួតពិនិត្យការងារដែលនគរបាលមានវត្តមានមុនគេបង្អស់បានធ្វើសកម្មភាពដំបូង
- ក្នុងករណីជួបប្រទះបញ្ហាស្មុគស្មាញធ្ងន់ធ្ងរត្រូវអញ្ជើញអ្នកសម្របសម្រួលកន្លែងកើតហេតុបានចូលរួម។ អ្នកសម្របសម្រួលកន្លែងកើតហេតុ គឺជានគរបាលថ្នាក់ដឹកនាំនៃនាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ដែលត្រូវបានគេស្នើសុំឲ្យចូលរួមនៅកន្លែងកើតហេតុក្នុងករណីមានឧបទ្វរហេតុធ្ងន់ធ្ងរ ហើយអ្នកសម្របសម្រួលកន្លែងកើតហេតុ មានភារកិច្ចជាអ្នកផ្សារភ្ជាប់ទំនាក់ទំនងរវាងបុគ្គលផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ បុគ្គលិកផ្នែកព្រហ្មទណ្ឌ និងបណ្តាផ្នែកសំខាន់ផ្សេងទៀត។ចំពោះវិធីសាស្ត្ររបស់ក្រុមរួមមានៈ
    - ជួបជុំគ្នានៅទីតាំងប្រមូលផ្តុំក្រៅរង្វង់កើតហេតុ។
    - ពិនិត្យមើលសកម្មភាពបែបណាខ្លះដែលត្រូវចូលកាន់ទីកន្លែងកើតហេតុ
    - បង្កើតគណៈកម្មាធិការត្រួតពិនិត្យទីកន្លែងកើតហេតុ
    - ក្រោយបង្កើតគណៈកម្មាធិការរួចហើយគណៈកម្មាធិការនេះត្រូវពិភាក្សាបើកយុទ្ធនាការចូលកាន់កន្លែងកើតហេតុ

➢ បែងចែកឲ្យជំនាញណាមួយអនុវត្ត មុនពេលឲ្យជំនាញណាមួយអនុវត្តបន្តបន្ទាប់ ហើយជំនាញនីមួយៗអ្នកណាធ្វើអ្វីខ្លះ ដូចនេះត្រូវពិភាក្សាឲ្យបានច្បាស់ដើម្បីជៀសវាង កុំឲ្យកិច្ចប្រតិបត្តិការត្រួតពិនិត្យទីកន្លែងកើតហេតុក្លាយទៅជាការបំផ្លាញទីកន្លែងកើតហេតុ តាមរយៈនៃការបែងចែកភារកិច្ចមិនបានច្បាស់លាស់។

### ៤.១.៤. ការបែងចែកទីកន្លែងកើតហេតុ

ចំពោះការបែងចែកនៅទីកន្លែងកើតហេតុ ត្រូវអនុវត្តដូចតទៅ:

- កំណត់ចារិកនៃរឿងហេតុ
- ណែនាំមន្ត្រីឲ្យប្រុងប្រយ័ត្នក្នុងការការពារភស្តុតាង និងស្លាកស្នាមផ្សេងៗទៀតដែលយល់ឃើញថាមានប្រយោជន៍ក្នុងការធ្វើកោសល្យវិច្ច័យ។
- ណែនាំមន្ត្រីបច្ចេកទេសឲ្យមានការប្រុងប្រយ័ត្នបើមានការសង្ស័យថា ទីកន្លែងកើតហេតុមានជាតិផ្ទុះឆេះសាធាតុគីមីដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់រាងកាយ ឬ អាយុជីវិត។
- ត្រូវចេះពន្យល់អប់រំដល់ជនរងគ្រោះ ឬគ្រួសាររបស់អ្នករងគ្រោះឲ្យយល់ពីសារៈសំខាន់កិច្ចសហប្រតិបត្តិការ។
- ត្រួតពិនិត្យមើលក្នុងកន្លែងកើតហេតុថាតើមានជនរងគ្រោះប៉ុន្មាននាក់ ហើយជនរងគ្រោះណាដែលចាំបាច់ត្រូវជួយសង្គ្រោះអាយុជីវិត ឬបញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់ និងត្រូវធ្វើការសាកសួរយកពត៌មានមុនគេបាត់បង់ជីវិត។
- មន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រជាអ្នកធ្វើកំណត់ហេតុនៃទីកន្លែងកើតហេតុទាំងមូល។

រាល់បណ្តាលភស្តុតាងនៅកន្លែងកើតហេតុ ឬ ក្រោយពេលដកហូតពីកន្លែងកើតហេតុ និងភស្តុតាងផ្សេងៗត្រូវបានមន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រជាអ្នកគ្រប់គ្រង ដែលចាំបាច់ត្រូវអញ្ជើញអ្នកឯកទេសមកឲ្យចូលរួមធ្វើការរហូតដើម្បីជៀសវាងគ្រោះថ្នាក់បាត់បង់ស្លាកស្នាម ឬខូចខាតភស្តុតាងដោយចៃដន្យ។

មន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រដែលជាអ្នកគ្រប់គ្រង និងចាត់ចែងភារកិច្ចត្រូវធ្វើការវាយតម្លៃជំហានដំបូងថាកន្លែងកើតហេតុណាជាកន្លែងកើតហេតុជាក់ស្តែង ហើយកន្លែងណាជាកន្លែងកើតហេតុបន្ទាប់បន្សំ ឬជាកន្លែងកើតហេតុបន្ទាប់ៗហើយមានភារកិច្ចកំណត់ច្រក ឬផ្លូវចេញចូលដើម្បីធានាសុវត្ថិភាពកន្លែងកើតហេតុបានល្អ១០០%។

រាល់បណ្តាទីកន្លែងកើតហេតុ ត្រូវតែធ្វើការថតរូប ថតវីដេអូដំបូងគេបំផុតពិសេសថតអំពីស្ថានភាពរួមទាំងទីកន្លែងកើតហេតុឲ្យបានគ្រប់ជ្រុង គ្រប់ទិសបើអាចធ្វើបាន ហើយឈានចូលទៅថតនៅក្នុងកន្លែងកើតហេតុ មន្ត្រីថតរូបត្រូវដើរក្រោយមន្ត្រីពិនិត្យហេតុជាដាច់ខាត។ មន្ត្រីគ្រប់ទីកន្លែងកើតហេតុក្រោយពិនិត្យពិចារណាដោយយកចិត្តទុកដាក់ កន្លែងកើតហេតុដំបូងឃើញទីកន្លែងកើតហេតុមានស្នាមប្រយោដៃមន្ត្រីគ្រប់គ្រង ត្រូវឲ្យអ្នកជំនាញខាងលើចូលមុនដើម្បីដាក់លេខឬសញ្ញាសម្គាល់ដើម្បីជៀសវាងបាត់បង់ស្លាកស្នាមទាំងនោះ។

បើកន្លែងកើតហេតុមានការពាក់ព័ន្ធដល់អ្នកជំនាញអាវុធជាតិផ្ទុះ ត្រូវឲ្យអ្នកជំនាញនោះ។ ដោយឡែកមន្ត្រីបច្ចេកទេសដែលជាអ្នកពិនិត្យ និង ធ្វើកំណត់ហេតុដោយអនុវត្តទៅតាមជំនាញកំណត់ហេតុ។

នៅកន្លែងកើតហេតុនៃបទល្មើសព្រហ្មទណ្ឌទោះជាបទល្មើសប្រភេទណាក៏ដោយ ក៏វាមិនមានលក្ខណៈខុសប្លែកពីគ្នានោះឡើយ។ ដូចនេះការងារអនុវត្តជំនាញបច្ចេកទេសធ្វើកោលវិថ្វ៍យក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាដែរ លើកលែងបទល្មើសមួយចំនួនដែលបានបង្កឲ្យមានមនុស្សស្លាប់ ឬ ក៏កន្លែងកើតហេតុដែលគេកត់សម្គាល់ថាមានសាធាតុពុល មានជាតិផ្ទុះ។ល។ ដែលទាមទារឲ្យមានការចូលរួមពីគ្រូពេទ្យតុលាការ ឬ អ្នកឯកទេសជំនាញផ្សេងៗទៀត។

### ៤.១.៥. ការថែរក្សា និង ការគ្រប់គ្រងភស្តុតាង ឬ វត្ថុតាង

ក្បួននីតិវិធីប្រតិបត្តិការ របស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានប្រកាសឲ្យប្រើប្រាស់ដោយក្រសួងមហាផ្ទៃលេខ ០៣៤ ប្រកាសចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៩៩៨ នៅទំព័រទី ២-១៥ បានកំណត់អំពីវិធីថែរក្សាភស្តុតាង និងវត្ថុតាងក្រោយពេលដែលប្រមូលបានពីកន្លែងកើតហេតុ ហើយតាមរបៀបដូចខាងក្រោមនេះ៖

- សំគាល់បំណែកវត្ថុតាងនីមួយៗដោយអត្តលេខ និងឈ្មោះមន្ត្រីដែលរកឃើញបំណែកវត្ថុតាងនេះ។
- បើអាចធ្វើបានត្រូវដាក់ភស្តុតាង ឬវត្ថុតាងនៅក្នុងប្រអប់ ឬក៏ស្រោមសំបុត្រឲ្យបានត្រឹមត្រូវល្អ។
- ចំពោះប្រអប់ ឬក៏ស្រោមសំបុត្រដែលបានរក្សាភស្តុតាង ឬវត្ថុតាងនៅក្នុងត្រូវបិទផ្លាកសំគាល់ឲ្យបានច្បាស់ដែលមាន
- សរសេរពត៌មានយ៉ាងត្រឹមត្រូវដើម្បីងាយស្រួលដល់ការស្វែងរក ឬក៏ងាយស្រួលនឹងរកឃើញ។ ពត៌មានទាំងនេះរួមមាន៖
    - កត់ត្រាពត៌មានសង្ខេបពីភស្តុតាង ឬវត្ថុតាង

- ឈ្មោះអ្នកប្រមូល ការបរិច្ឆេទប្រមូល
- ទីកន្លែងដែលភស្តុតាងត្រូវបានប្រមូលទុក
- ឈ្មោះរបស់ជនសង្ស័យ
- លេខសំណុំរឿង។
- បិទប្រអប់ ឬស្រោមសំបុត្រផ្ទុកវត្ថុតាងដោយបង់ស្អិតគូសកន្លែងដោយបិចតាត់លើបង់ស្អិតហួសទៅលើប្រអប់ ឬស្រោមសំបុត្រហើយអ្នកបិទប្រអប់ ឬស្រោបសំបុត្រត្រូវចុះហត្ថលេខាកាត់លើបង់ស្អិត និងចុះហត្ថលេខាកាត់លើបង់ស្អិត និងចុះកាលបរិច្ឆេទដែលស្រោមសំបុត្រ ឬប្រអប់នោះត្រូវបានបិទ។
- ថែរក្សាសំបុត្រ ឬស្រោបសំបុត្រដាក់ភស្តុតាង ឬ វត្ថុតាងនៅក្នុងកន្លែងដែលមានសុវត្ថិភាពការពារឲ្យរួចផុតពីការខូចខាតដោយអាកាសធាតុ។
- បើភស្តុតាង ឬ វត្ថុតាងត្រូវបានប្រគល់ឲ្យទៅអ្នកផ្សេង( ដូចជា ព្រះរាជអាជ្ញា ចៅក្រម ឬ មន្ត្រីនគរបាលយុត្តិធម៌ ) ត្រូវតែធ្វើកំណត់ហេតុឲ្យបានពិស្តារ ស្តីពីការផ្ទេរប្រគល់នោះ។

នីតិវិធីទាំងអស់នេះ មានសារៈសំខាន់ចាំបាច់ដើម្បីធានាមិនឲ្យភស្តុតាងត្រូវខូចខាតបំផ្លេចបំផ្លាញពេលបញ្ជូនទៅដល់តុលាការឡើយ។ គោលការណ៍នេះហៅថា "ខ្សែសង្វាក់ថែរក្សាវត្ថុតាង" មានន័យថានៅពេលដែលភស្តុតាងត្រូវបានប្រមូលយកពីកន្លែងកើតហេតុមួយ ឬពេលជនណាម្នាក់នគរបាលត្រូវកត់ត្រានូវសេចក្តីរាយការណ៍ ឲ្យល្អិតល្អន់ពីជនគ្រប់រូបដែលយកបានភស្តុតាងទាំងនោះ។ ជនម្នាក់ៗនោះត្រូវបានចាត់ទុកជាទំនាក់ទំនងផ្ទេរបន្តក្នុង "ខ្សែសង្វាក់ថែរក្សាភស្តុតាង" ។

### ៤.១.៦. ការធ្វើកំណត់ហេតុពិនិត្យកន្លែងកើតហេតុ

ជាគោលការណ៍មន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រត្រូវចាត់ចែងធ្វើការកត់ត្រាឲ្យបានល្អិតល្អន់អំពីភូមិសាស្ត្រកន្លែងកើតហេតុទាំងខាងក្នុងនិងខាងក្រៅ និង កន្លែងកើតហេតុបន្ទាប់ដោយយកចិត្តទុកដាក់ពិនិត្យពិច្ច័យ និងកត់ត្រាឲ្យបានជាក់លាក់អំពីស្លាកស្នាមផ្សេងៗដែលជាភស្តុតាង ឬវត្ថុតាងនានាដែលបន្សល់ទុក។

ក្នុងករណីមនុស្សស្លាប់ត្រូវកត់ត្រាអំពីស្ថានភាពនៃការស្លាប់ និងអត្តសញ្ញាណសាកសព។ល។ ភស្តុតាង និង វត្ថុតាងដែលបានរកឃើញនូវកន្លែងកើតហេតុត្រូវតែកត់ត្រាឲ្យបានច្បាស់លាស់បំផុតនូវទ្រង់ទ្រាយ ពណ៌សម្បុរ ទំហំ ប្រភេទ ស្ថានភាព គុណភាព ព្រមទាំងទីតាំងស្ថិតនៅទៀងផង។ មុនធ្វើការប្រមូលត្រូវថតរូបភាពវត្ថុតាងជៀសវាងការបាត់បង់ ឬត្រូវបំផ្លាញ។

ដោយមានការចង្អុលបង្ហាញពី មន្ត្រីពិនិត្យហេតុការថតរូបភាពត្រូវធ្វើឡើងឲ្យបានល្អិតល្អន់គ្រប់កន្លែង និងគ្រប់ទិសទាំងស្ថានភាពរួម ទាំងរូបភាពស្លាកស្នាម ទាំងរូបភាពវត្ថុតាងនីមួយៗដោយមានការកត់ត្រាជាក់លាក់តាមលំដាប់លំដោយ។ ប្រការនេះក៏អាចជាជំនួយយ៉ាងល្អសម្រាប់បញ្ជាក់ដល់អ្នកមិនបានចូលរួមអនុវត្តការងារនៅន្លែងកើតហេតុដោយផ្ទាល់ ដើម្បីយល់បានអំពីទីតាំងនៃបំណែកវត្ថុតាង និងស្ថានភាពរបស់វត្ថុតាងទាំងនោះនៅកន្លែងកើតហេតុផងដែរ។

ជាមួយគ្នានឹងការកត់ត្រាខាងលើ គំនូសប្លង់កន្លែងកើតហេតុត្រូវតែបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងច្បាស់លាស់។ គំនូសប្លង់នេះពុំចាំបាច់មានការកំណត់មាត្រដ្ឋាននោះទេ តែត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទំហំកន្លែងកើតហេតុ អំពីទីតាំងនឹងត្រូវបញ្ជាក់ជាតួលេខឲ្យបានច្បាស់អំពីទាំងស្លាកស្នាម ភស្តុតាង វត្ថុតាងដោយប្រើជញ្ជាំង អាគារ ឬអចលនវត្ថុអ្វីមួយនៅក្នុងបរិវេណកន្លែងកើតហេតុសម្រាប់ធ្វើជាគោលវាស់វែង។

កាលបើបានរូបភាព និងគូសប្លង់រួចហើយមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រត្រូវចាប់ផ្តើមប្រមូលយកវត្ថុតាង។ បើអាចធ្វើទៅបានគេត្រូវប្រមូលយកភស្តុតាងដែលនៅលើកំរាល ឬនៅលើដីមុនគេដើម្បីជៀសវាង កុំឲ្យភស្តុតាងទាំងនោះខូចខាត ឬប្រលាក់ក្រលូសដោយអ្នកធ្វើដំណើរទៅមករបស់សមត្ថកិច្ច។

ដើម្បីឲ្យបណ្តាភារកិច្ចដូចពៀលខាងលើប្រព្រឹត្តទៅទទួលបានលទ្ធផលល្អគាប់ប្រសើរមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ត្រូវមានវិធានការឲ្យបានម៉ឺងម៉ាត់ហាមឃាត់ចំពោះការចេញចូលកន្លែងកើតហេតុចំពោះអ្នកដែលគ្មានសិទ្ធិអនុញ្ញាតទោះបីជាកម្លាំងនគរបាលកងរាជអាវុធហត្ថ អ្នកសារព័តមាន អង្គការក្រៅរដ្ឋាភិបាល។ល។

### ៤.១.៧. ការគ្រប់គ្រងកំណត់ហេតុ

កំណត់ហេតុដែលត្រូវដាក់ឲ្យអនុវត្តនៅកន្លែងកើតហេតុមានជាអាទិ៍:

- កំណត់ហេតុពិនិត្យកន្លែងកើតហេតុ (កត់ត្រាអំពីសកម្មភាពបទល្មើស និងស្លាកស្នាម) វត្ថុតាង
- កំណត់ហេតុរូបថត
- គំនូសប្លង់កន្លែងកើតហេតុ
- កំណត់ហេតុដកហូតវត្ថុតាង (រាល់វត្ថុដែលជាប់ពាក់ព័ន្ធដល់សកម្មភាពបទល្មើស ឬ វត្ថុ-តាងដែលមានជាប់ស្លាកស្នាម ឬមធ្យោបាយប្រព្រឹត្តបទល្មើស)

- កំណត់ហេតុសាកសួរបំភ្លឺ (ពិតមានសាក្សីនៅជុំវិញកន្លែងកើតហេតុ មុនកើតហេតុ ក្រោយកើតហេតុ ពេលកើតហេតុ និងភ្ជាប់ដោយសាលាកបត្រ ភិនភាគមុខសញ្ញា
- កំណត់ហេតុប្រគល់ទទួល (កំណត់ហេតុធ្វើឡើងក្រោយពេលបញ្ចប់ពិនិត្យកន្លែងកើតហេតុ)
- របាយករណ៍បូកសរុបវាយតម្លៃករណីរឿងបម្រើឲ្យករណីស៊ើបអង្កេត (របាយការណ៍នេះធ្វើឡើងដោយប្រធានគ្រប់គ្រងកន្លែងកើតហេតុ ចូលរួមវាយតម្លៃសន្និដ្ឋានដោយសមាជិកគណៈកម្មាធិការពិនិត្យស្រាវជ្រាវកន្លែងកើតហេតុ)

ចំពោះកំណត់ហេតុទាំងអស់ដែលរៀបរាប់ខាងលើនេះ ត្រូវគ្រប់គ្រងដោយនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ។

### ៤.១.៨. សមាសភាពផ្នែកជំនាញនៃនគរបាលបច្ចេកទេសវិទ្យាសាស្ត្រដែលមានភារកិច្ចប្រមូលភស្តុតាង

ជាទូទៅ ផ្នែកជំនាញក្នុងការប្រមូលភស្តុតាងនៃនគរបាលបច្ចេកទេសវិទ្យាសាស្ត្រនៅកន្លែងកើតហេតុក្រោមកិច្ចចង្អុលណែនាំរបស់មន្ត្រីពិនិត្យកន្លែងកើតហេតុ នៃនគរបានបច្ចេកទេសវិទ្យាសាស្ត្រនៅកន្លែងកើតហេតុរួមមាន៖

- ផ្នែកថតរូប
- ផ្នែកកោសល្យវិច្ច័យអាវុធ
- ផ្នែកកោសល្យវិច្ច័យស្នាមក្រយៅដៃ ជើង

ទោះបីជាយ៉ាងនេះក្តី ក្នុងករណីគេសង្ស័យថានៅកន្លែងកើតហេតុអាចមានសារធាតុគីមីជីវសាស្ត្រជាតិពុលផ្សេងៗ ឬក៍ជាជាតិផ្ទុះដែលប៉ះពាល់ដល់សុខភាព និងយាយីដល់អាយុជីវិតមនុស្សបាននោះ មន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រដោយមានការសម្របសម្រួលពីលោកព្រះរាជអាជ្ញាត្រូវធ្វើការអញ្ជើញអ្នកឯកទេសជំនាញពាក់ព័ន្ធឲ្យមកចូលរួមសហការ ដោះស្រាយដោយយោងទៅតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែងនៅកន្លែងកើតហេតុ។

## ៤.២.ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង

ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី៧ថ្ងៃ គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។កិច្ចស៊ើបអង្កេតត្រូវបានប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ។ ប្រសិនបើការស៊ើបអង្កេត មិនបានបញ្ចប់ក្នុងរយៈពេល៧ថ្ងៃទេនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះ-

រាជអាជ្ញា[16] ។ ចំពោះថិរវេលាក្នុងការឆែកឆេរ បទល្មើសជាក់ស្តែងនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានគ្រប់ពេលវេលា ពោលគឺអាចចូលឆែកឆេរ ២៤ម៉ោង លើ២៤ម៉ោង មិនថាពេលយប់ឬថ្ងៃទេ។ ក្នុងករណីបទល្មើសជាក់ស្តែងអនុលោមតាមមាត្រា៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៩ នគរបាលយុត្តិធម៌អាចផ្តួចផ្តើមបើកកាស៊ើបអង្កេតលើករណីដូចជា មានសម្រែកឲ្យជួយពីខាងក្នុងទីកន្លែង ឬក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងម៉ោងដែលបើចំហដល់សាធារណជន និងនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ករណីនេះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញាទោះបីជា ការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ[17]។

ក្រោយពីថិរវេលានេះ ការស៊ើបអង្កេតនឹងត្រូវបានបន្តធ្វើក្នុងក្របខ័ណ្ឌការស៊ើបអង្កេតបឋម ឬ ក្នុង ក្របខ័ណ្ឌការស៊ើបសួរ ។

### ៤.៣.វិធានការស្រាវជ្រាវ

នីតិវិធីស៊ើបអង្កេតករណីជាក់ស្តែង ទោះបីជាការស៊ើបអង្កេតត្រូវបានធ្វើឡើងក្រោមរូបភាពណាក៏ដោយ បទល្មើសជាក់ស្តែង ការស៊ើបអង្កេតបឋម ឬដីកាចាត់អោយស៊ើបសួរជំនួស កិច្ច-ស្រាវជ្រាវនានាដែលត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ គឺមានលក្ខណៈដូចគ្នាទាំងអស់[18] ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការត្រួតពិនិត្យរបស់ខ្លួន[19]។

#### ៤.៣.១. វិធានការដំបូង

ក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទ-ល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឲ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ប្រសិនបើយល់ថាមានប្រយោជន៍ ព្រះ-រាជអាជ្ញាចុះទៅ កាន់កន្លែងកើតហេតុនិងដឹកនាំការស៊ើបអង្កេត។ ប្រសិនមានការបន្ទាន់ព្រះរាជ-អាជ្ញាអនុញ្ញាតឲ្យនគរ បាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិដោយគោរពតាមលក្ខខណ្ឌ (ការពន្លាតសមត្ថកិច្ចដែនដី)[20] ។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០៦
[17] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨១
[18] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨៥ ដល់ ១១០ ៧
[19] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៩០
[20] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៦៨

ជាទូទៅ មន្ត្រីនគរបាលយុត្តិធម៌មានអំណាចមួយចំនួនដែលហៅថា « អំណាចបង្ខំ » ទាក់ទងនឹង៖

### ៤.៣.២. ការចាប់ខ្លួន

ការចាប់ខ្លួន ជាការដាក់ឲ្យជនសង្ស័យស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីនគរបាល ឬឲ្យព្រះរាជអាជ្ញា ដើម្បីធ្វើការសាកសួរស្វែងតម្រុយបទល្មើសបន្ថែម។ ក្នុងកាលៈទេសៈជាច្រើន ការចាប់ខ្លួនច្រើនធ្វើឡើងនៅទីកន្លែងកើតហេតុក្នុងពេលប្រព្រឹត្តបទ ឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយដែលជាបទល្មើសជាក់ស្តែង។ លក្ខណៈនៃការចាប់ខ្លួនដែលយកទៅប្រើ គឺអាស្រ័យទៅលើសភាពការ-ណ៍។ ក្នុងករណីខ្លះ នគរបាលអាចពិនិត្យសភាពការណ៍បានដោយជៀសវាងប្រើកម្លាំង តែក្នុងករណីខ្លះទៀតនគរបាលត្រូវប្រើកម្លាំង។ ក្នុងករណីបែបនេះកម្លាំងដែលប្រើនោះ ត្រូវឲ្យស្ថិតនៅក្នុងបរិមាណសមល្មម និងបើមិនចាំបាច់កុំឲ្យលើសពីការតបតរបស់ជនល្មើសហួសហេតុ។

### ៤.៣.៣.ការឆែកឆេរ

ការឆែកឆេរ ត្រូវតែគោរពឲ្យបានតឹងរឹងបំផុតទៅលើលក្ខខណ្ឌ និងនីតិវិធីដែលចែង ក្នុងមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ មាត្រានេះបញ្ជាក់ជូនថា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការ ឆែក ឆេរបាន។ ក្នុងករណីនេះមន្ត្រីនគរបាលធម៌មិនចាំបាច់មានដីកាពីតុលាការទេ ប៉ុន្តែគាត់ត្រូវមានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ហើយការអនុញ្ញាតអាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ដូចនេះនៅពេលដែលគាត់បានទទួលការអនុញ្ញាតជាបឋម គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដែលកាឆែកឆេរត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចជា ការឆែកឆេរត្រូវធ្វើនៅចំពោះមុខសាក្សីពីររូប ដែលសាក្សីនេះត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបានចុះដឹកនាំប្រតិបត្តិការ ។

យោងតាមគោលការណ៍ដែលមានចែងនេះ គឺត្រូវជ្រើសរើសអ្នកដែលមិនមានជាប់ពាក់ពន្ធ័ជាមួយនឹងប្រតិបត្តិការ បានន័យថាសាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកម្លាំងរួម ប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ដូច្នេះសាក្សីត្រូវជ្រើសរើសចេញពីអ្នកដែលមិនបានចូលរួម ក្នុងប្រតិបត្តិការនៃការឆែកឆេរនោះ។ ចំណុចមួយផ្សេងទៀតគឺទាក់ទងនឹងម៉ោងសម្រាប់ធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង១៨ (ដប់ប្រាំបី) ឡើយ លើកលែងតែ ៖

- បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង
- ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

- ក្នុងករណីដែលមានសម្រែកស្រែកឲ្យជួយពីក្នុងទីកន្លែង
- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងម៉ោងដែលបើកចំហដល់សាធារណជន

ឧទាហរណ៍: កន្លែងដែលបើកពេលយប់មានបនពេស្យា បនល្បែង ឬ រង្គសាលរាំកំសាន្តជាដើម គឺអាចធ្វើការឆែកឆេរបាន ព្រោះគេបើកចំហរដល់សាធារណជន នៅពេលយប់ខុសពីម៉ោង ៦ ព្រឹក ដល់ ៦ល្ងាច ដូច្នេះអាចធ្វើការឆែកឆេរដោយមិនគោរពលក្ខខណ្ឌពេលវេលានៃការឆែកឆេរបាន។

- ក្នុងករណីឆែកឆេរនៅគ្រប់កន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿង-ញៀន ។ នេះជាវិធានការពិសេសមួយដែលទាក់ទងនឹងបទល្មើសគ្រឿងញៀន។ ករណីនេះមិនចាំបាច់គោរពវិធានទាក់ទងនឹងពេលវេលាចាប់ពីម៉ោង ៦ព្រឹក ដល់ ៦ល្ងាចឡើយ ។
- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និង ម៉ោងនៃការអនុញ្ញាតនេះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ របស់សាក្សីនីមួយៗ ។

ចំពោះលក្ខខណ្ឌពិសេសដោយអ្នកមានវិជ្ជាជីវៈពីរ គឺ វិជ្ជាជីវៈមេធាវី និង វិជ្ជាជីវៈសារពត៌មាន ផ្លូវច្បាប់បានគាំពារវិជ្ជាជីវៈទាំងនេះក្នុងក្រមខ័ណ្ឌនីតិវិធីព្រហ្មទណ្ឌ ដោយហាមឃាត់មន្ត្រីនគរបាលយុត្តិធម៌មិនឲ្យធ្វើការឆែកឆេរចំពោះការិយាល័យមេធាវីបានឡើយ ។ ការឆែកឆេរអាចធ្វើបានដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ហើយការឆែកឆេរនេះត្រូវធ្វើឡើងនៅចំពោះមុខ ប្រធានគណៈមេធាវី ឬប្រតិភូប្រធានគណៈមេធាវី ឬមេធាវីសាមី។ ដូច្នេះចំណុចនេះជាការការពារមួយ ចំពោះវិជ្ជា-ជីវៈមេធាវី ដែលមន្ត្រីនគរបាលយុត្តិធម៌មិនអាចរំលោភបានឡើយ ។

ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់បានការពារផងដែរចំពោះវិជ្ជាជីវៈសារព័ត៌មានទាំងសារព័ត៌ មានសរសេរ ទាំងសារព័ត៌មានសោតទស្សន៍គឺ បានន័យថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មានដោយឯកឯងបានទេ គាត់ត្រូវធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬ ចៅក្រម ស៊ើបសួរ។ ហេតុអ្វីចាំបាច់មានវត្តមានព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរនៅពេលធ្វើការឆែកឆេរក្នុង សហគ្រាសទាំងនោះ? ព្រោះគាត់ជាអ្នកធានារ៉ាប់រងកុំអោយមានការឆែកឆេរក្លាយជាការរំលោភបំពានដែលនាំឲ្យមានការឃើតយ៉ាវក្នុងការប្រកបវិជ្ជាជីវៈដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឲ្យឃើតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាន ។

ឧទាហរណ៍៖ មន្រ្តីនគរបាលយុត្តិធម៌គាត់ឆែកឆេរដោយបំពានដោយសារគាត់ទៅឆែកឆេរការិយាល័យមេធាវី ឬអគារព័ត៌មានដោយឯកឯង ក្នុងករណីនេះការឆែកឆេរត្រូវចាត់ទុកជាមោឃៈបានន័យថាអ្វី ដែលទទួលបាននៅក្នុងនីតិវិធីនោះ គឺមិនអាចយកជាបានការឡើយ[21] ។

### ៤.៣.៤.ការបិទស្លាកបោះត្រាលើវត្ថុតាង

ការបិទស្លាកបោះត្រាលើវត្ថុតាង ការឆែកឆេរ មន្រ្តីនគរបាលយុត្តិធម៌បានរកឃើញនូវវត្ថុដែលគួរឲ្យសង្ស័យគាត់មានសិទ្ធិអំណាច ចាប់យកវត្ថុតាង[22]នោះបាន បន្ទាប់មកមន្រ្តីនគរបាលយុត្តិធម៌ត្រូវវេចខ្ចប់ភស្តុតាងនេះទុក។ គាត់ត្រូវ មានសាក្សីពីរនាក់ ឬអ្នកកាន់កាប់ទីកន្លែងថាគាត់បានចាប់ភស្តុ-តាងនេះហើយ គាត់បានចាប់យកទៅវេចខ្ចប់ ហើយពេលដែលវេចខ្ចប់ហើយ ត្រូវមានបិទស្លាក និងបោះត្រាដើម្បីរក្សាថាមិនមានការលួចដូរនោះឡើយ។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលគាត់បញ្ចប់ប្រតិបត្តិការរបស់ខ្លួនគាត់ត្រូវធ្វើបញ្ជីសារពើភណ្ឌ នៃវត្ថុតាងទាំងឡាយ ដែលបានចាប់យកហើយដោយត្រូវភ្ជាប់ជាមួយកំណត់ហេតុនៃការឆែកឆេរមួយ ទៀត កំណត់ហេតុនៃការឆែកឆេរត្រូវកំណត់ឲ្យបានច្បាស់ អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជព្រះរាជអាជ្ញាគាត់ផ្តល់ការអនុញ្ញាតឲ្យ ហើយការអនុញ្ញាតអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយអ្នកចូលរួមមានន័យថា សំដៅជាពិសេសទៅដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីររូបដែលមានវត្តមាន ហើយដាច់ខាតត្រូវតែមានគាត់ចុះហត្ថលេខា ឬផ្តិតម្រាមដៃ។

[21] យោងតាមប្រសាសន៍របស់ឯកឧត្តមកើតរិទ្ធ អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិ វិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

[22] យោងតាមប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី, អគ្គនាយកស្រាវជ្រាវ និង អភិវឌ្ឍន៍វិស័យយុត្តិធម៌នៃក្រសួងយុត្តិធម៌នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

# ជំពូកទី២
# ការស៊ើបអង្កេតបឋម

## ផ្នែកទី ១ ការស៊ើបអង្កេតបឋម

ផ្ទុយពីសញ្ញាណជាក់ស្តែង ការស៊ើបអង្កេតបឋម ពុំត្រូវបានកំណត់និយមន័យ ក្នុងក្រមនីតិ-វិធីព្រហ្មទណ្ឌទេ ។ ការស៊ើបអង្កេតបឋមគឺ ជាឧបករណ៍នៃនីតិរូប ( នីតិវិធីស៊ើបអង្កេតធម្មតា ) ដែលនគរបាលយុត្តិធម៌មានដើម្បីពិនិត្យកត់ត្រាបទល្មើស និង ស្វែងរកអ្នកប្រព្រឹត្តនៅពេលដែលពុំមានបើកការស៊ើបសួរ ឬ នៅពេលដែលអ្នកស៊ើបអង្កេតមិនអាចធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬ បដិសេធការស៊ើបអង្កេតបែបនេះ។ ការស៊ើបអង្កេតមានគោលបំណងបំភ្លឺ ព្រះរាជអាជ្ញាមុនពេលចេញសេចក្តីសម្រេចដាក់ពាក្យបណ្តឹង។

### ១.១.បុព្វហេតុនៃការស៊ើបអង្កេត

ការស៊ើបអង្កេតបឋមអាចត្រូវបានបើកការស៊ើបអង្កេត ដោយមន្ត្រីនគរបាលយុត្តិធម៌ដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ការស៊ើបអង្កេតនេះទាក់ទិននឹងគ្រប់បទល្មើសទាំងអស់ ( បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ )។ ផ្ទុយពីការស៊ើបអង្កេតបទល្មើសជាក់ស្តែង ជាគោលការណ៍ការស៊ើបអង្កេតបទល្មើសបឋមមិនត្រូវបានកំណត់ពេលវេលាទេ។

### ១.២. លក្ខណៈទូទៅនៃការស៊ើបអង្កេត

នៅក្នុងក្រមបារាំង កំណត់ហេតុដែលតាក់តែងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខណ្ឌការស៊ើបអង្កេតបឋមត្រូវដាក់ជូនចៅក្រមពិចារណាដោយសេរី។ ក៏ប៉ុន្តែ កំណត់ហេតុដែលពិនិត្យកត់ត្រាបទលហុ ត្រូវទុកជាបានការរហូតដល់មានភស្តុតាងផ្ទុយ។ នៅកម្ពុជាមាត្រា១១៨ និង មាត្រា១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌហាក់ដូចជាចង្អុលបង្ហាញនៅភាពផ្ទុយគ្នា និង ផ្ទុយទៅនឹងមាត្រា ៣២១ ។ ប៉ុន្តែវិធាននៃជំនឿស៊ប់របស់ចៅក្រម ហាក់ដូចជាមានឧត្តមភាពជាង។

នេះមានន័យថាកំណត់ហេតុ និង របាយការស៊ើបអង្កេតដែលត្រួតពិនិត្យ បទឧក្រិដ្ឋ ឬ បទ-មជ្ឈិម មានតម្លៃត្រឹមតែជាពត៌មានធម្មតាប៉ុណ្ណោះ។ កំណត់ហេតុដែលធ្វើក្នុងពេលស៊ើបអង្កេតអាចយកជាការបានតែចំពោះភាព ជាវត្ថុនៃចម្លើយ ឬការពិនិត្យដែលកត់ត្រាទុកក្នុងកំណត់ហេតុតែប៉ុណ្ណោះ ប៉ុន្តែ ភាគីរក្សាសិទ្ធិក្នុងការពិភាក្សាចម្លើយ ឬការពិនិត្យទាំងនេះ ហើយចៅក្រមដែលមានសេរីភាព កំណត់តម្លៃជាភស្តុតាងនៃចម្លើយ និង ការពិនិត្យដោយផ្អែកទៅលើជំនឿនៃធម្មារម្មណ៍របស់ខ្លួន ។

ច្បាប់បានផ្តល់តម្លៃជាភស្តុតាងសំខាន់ដល់កំណត់ហេតុខ្លះៗ ដែលអាចចោទជាបញ្ហាបានតែក្នុងករណីមួយចំនួន ជាអាទិ៍កំណត់ហេតុដែលតម្លៃនៃភស្តុតាង អាចចោទជាបញ្ហាបានតែក្នុងករណីដែលមានភស្តុតាងផ្ទុយពីអត្ថន័យរបស់វា។ វិធាននេះគឺ ទាក់ទិននឹងកំណត់ហេតុដែលពិនិត្យបទលហុ។

ទាក់ទងនឹងដំណើការនៃការស៊ើបអង្កេតបទល្មើសបឋម មាត្រា១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សំដៅដល់កិច្ចស៊ើបសួរដែលមានចែងលំអិតក្នុង ការស៊ើបអង្កេតជាក់ស្តែង ហើយដែលត្រូវអនុវត្តចំពោះការស៊ើបអង្កេតបឋម ។ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការពិនិត្យបច្ចេកទេស ឬ វិទ្យាសាស្ត្រ ត្រូវធ្វើការត្រួតពិនិត្យកត់ត្រាដែលមានប្រយោជន៍ និងធ្វើកំណត់ហេតុ។ លើសពីនេះនៅចុងបញ្ចប់នៃការស៊ើបមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនកំណត់ហេតុទាំងមូលព្រមទាំងវត្ថុតាងនានាជូនទៅព្រះរាជអាជ្ញា។

ទាក់ទងនឹងការឆែកឆេរ មាត្រា១១៣ បានបញ្ញាត្តថា កាលណាការស៊ើបអង្កេតបឋមនោះទាក់ទងនឹង បទឧក្រិដ្ឋ និង បទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និង ចាប់យកវត្ថុតាង។ មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និង ពិតប្រាកដ ពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ សរសេរដោយផ្ទាល់ដៃដោយអ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុង កំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីការឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់ នៅការឆែកឆេរនេះ។ ការឆែកឆេរនេះត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទីកន្លែងត្រូវធ្វើនៅ ចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនអាចជានគរបាល ឬ កងរាជអាវុធហត្ថ ជាកម្លាំងរួម ប្រតិបត្តិការក្នុងការឆែកឆេរ នោះឡើយ។ ការឆែកឆេរមិនអាចផ្តើមឡើងមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង១៨( ដប់ប្រាំបី ) ល្ងាចឡើយ។

បញ្ញាត្តនៃមាត្រា ៩២ ( ការបិទស្លាកបោះត្រា លើវត្ថុតាង ) នៃក្រមនេះត្រូវយកមកអនុវត្តក្នុងការចាប់យកភស្តុតាង។ ក៏ដូចគ្នាផងដែរ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចធ្វើការស្តាប់ទូរស័ព្ទ ចាប់ការឆ្លើយឆ្លងតាមទូរគមនាគមន៍។

ទោះជាការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបសួរអនុញ្ញាតឲ្យនគរបាល និងចៅក្រមអនុវត្តការបង្ខិតបង្ខំលើបុគ្គល និង អនុវត្តកិច្ចចាត់ចែងលើវត្ថុក៏ដោយ ក៏ការស៊ើបអង្កេតបទ-

ល្មើសបឋម អាចធ្វើបានតែក្នុងករណីដែលមានការចូលរួមសហការណ៍ពីអ្នកមានប្រយោជន៍ដោយដឹងរឿងហេតុប៉ុណ្ណោះ។

ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ មិនអាចសួរដេញដោលជនសង្ស័យ ដោយឯកឯងក្នុងទីកន្លែងរបស់ខ្លួនបានទេ ទោះបីជាខ្លួនមានអំណាចនេះ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងក៏ដោយ។ សាក្សី និង ជនសង្ស័យ មានរបបក្នុងការស្តាប់ចម្លើយដូចគ្នា។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងអំពីការកោះហៅជនសង្ស័យ ឬសាក្សីដែលមានកាតព្វកិច្ច ឆ្លើយតបនឹងការកោះហៅនេះ។ មន្ត្រីនគរបាលយុត្តិធម៌ អាចប្រើអំណាចបង្ខំ និង បង្ខិតបង្ខំបុគ្គលណាម្នាក់ឲ្យចូលខ្លួនចំពោះមុខ បើមានលិខិតបង្គាប់ឲ្យចូលខ្លួនដោយព្រះរាជអាជ្ញា ( មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាញចេញពីច្បាប់ចុះថ្ងៃទី ១០ សីហា ២០០៧ ) របបស្តាប់ចម្លើយនេះដូចគ្នាទៅនឹង របបស្តាប់ចម្លើយដែលបានលើកឡើង ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងផងដែរ។

ក្រៅពីនេះមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឃាត់ខ្លួនក្នុងករណីដែលការស៊ើបអង្កេតបឋមនេះ ធ្វើឡើងចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម។ បទប្បញ្ញត្តិដែលចែងសម្រាប់អនុវត្តក្នុងក្របខណ្ឌ ការស៊ើបអង្កេតជាក់ស្តែង ត្រូវអនុវត្តទាំងស្រុង។ ហេតុដូច្នេះ គួរចំណាំថា វិធានបែបនេះមិនអនុវត្តចំពោះជនសង្ស័យថាបានប្រព្រឹត្តបទលហុទេ។

## ផ្នែកទី២ សំណុំរឿង

សំណុំរឿងនីតិវិធីបានកសាងឡើងដោយការស៊ើបអង្កេតដែលឆាប់រហ័ស និង មានប្រសិទ្ធភាព ភាគីក្នុងនីតិវិធី ដូចជាព្រះរាជអាជ្ញា ដែលមានតួនាទីចម្បង និងជនរងគ្រោះដែលមានតួនាទីបន្ទាប់បន្សំ ត្រូវសម្រេចថានឹងធ្វើដូចម្តេចតទៅទៀត ដោយយោងនឹងភាពជាក់លាក់ និង ស្ថានភាពភស្តុតាងដែលប្រមូលបាន។

### ២.១ ចំណាត់ការសំណុំរឿង

ព្រះរាជអាជ្ញា ត្រូវធ្វើការសម្រេចបើខ្លួនចង់ធ្វើបណ្តឹងអាជ្ញា ចំពោះបទល្មើសដែលនីតិវិធីបានកសាង។ ទោះជាជនរងគ្រោះមានត្រឹមតែតួនាទីត្រឹមបន្ទាប់បន្សំក៏ដោយ ក៏ជននេះមានសិទ្ធស្វ័យសម្រេច ទៅលើការអនុវត្ត យថាហេតុនូវសិទ្ធក្នុងការបណ្តឹងរដ្ឋប្បវេណី ដែលជាញឹកញយអាស្រ័យទៅលើសេចក្តីសម្រេចរបស់បទប្បញ្ញត្តិនៃមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាផ្នែកមួយនៃវិធាន និងទម្រង់ការដែលបានចែង និងនាំឲ្យមានមោឃភាពក្នុងករណីដែលមិនគោរព[23]។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០៩ ។

នៅពេលដែលថិរវេលានេះត្រូវបានបញ្ចប់ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនទាន់បញ្ចប់ការស៊ើបអង្កេតមន្ត្រីនេះត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា ដែលនឹងពិនិត្យពិចារណាវាយតម្លៃអំពីភាពចាំបាច់ក្នុងការបន្តការស៊ើបអង្កេត ក្នុងក្របខ័ណ្ឌការស៊ើបអង្កេតបឋម ឬការស៊ើបសួរ តំកល់រឿងទុកឥតចាត់ការឬបញ្ជូនរឿងទៅសាលាជម្រះក្តីដោយផ្ទាល់។

បើការស៊ើបអង្កេតត្រូវបានបញ្ចប់ កំណត់ហេតុ និងភស្តុតាងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា បើពុំនោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី[24] ។ ក្នុងកំឡុងពេលស៊ើបអង្កេត គ្រប់កិច្ចទាំងអស់ត្រូវកត់ត្រានៅនឹងកន្លែងក្នុងកំណត់ហេតុ ដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលដឹកនាំការស៊ើបអង្កេតនេះ។ ក្រោយពីការស៊ើបអង្កេត គ្រប់ធាតុរបស់សំណុំរឿងទាំងមូល ( កំណត់ហេតុ និង វត្ថុតាង )ត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ។

## ២.២. កិច្ចស៊ើបអង្កេតបឋម

### ២.២.១ ការចុះទៅកាន់ទីកន្លែងកើតហេតុ

នៅពេលមន្ត្រីនគរបាលយុត្តិធម៌ ទទួលបានពត៌មានពីការប្រព្រឹត្តិបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនេះមានកាតព្វកិច្ចជាមួយនឹងព្រះរាជអាជ្ញា[25] ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យ និង កត់ត្រាជាប្រយោជន៍ និងធានារ៉ាប់រងរក្សាទុកនៅតម្រុយ និង ភស្តុតាងដែលអាចនឹងបាត់បង់។ នេះជាការអនុវត្តអំណាចពិនិត្យកត់ត្រាបទល្មើសទូទៅ ដែលប្រគល់ឲ្យដោយមាត្រា ៧២ នៃក្រមដែលកំណត់អំពីបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌។ ដើម្បីបំពេញបេសកកម្មនេះមន្ត្រីនគរបាលយុត្តិធម៌មានអំណាចហាមឃាត់បុគ្គលគ្រប់រូប កុំឲ្យទៅឆ្ងាយពីកន្លែងកើតហេតុរហូតទាល់តែបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ដើម្បីអាចឃាត់ទុកសាក្សីជាយថាហេតុណាមួយព្រមទាំងដើម្បី ទប់ស្កាត់ការរត់កិច្ចខ្លួនរបស់អ្នកប្រព្រឹត្ត។ មន្ត្រីនគរបាលយុត្តិត្រូវធ្វើកំណត់ហេតុស្តីពីការពិនិត្យកត់ត្រា និង ស្រាវជ្រាវរបស់ខ្លួន។ ព្រះរាជអាជ្ញាដែលធានារ៉ាប់រងដំណើការល្អនៃការស៊ើបអង្កេតអាចចុះទៅកាន់ទីកន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត។

### ២.២.២. ការឆែកឆេរ និងការចាប់យកវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរណាដែលមានប្រយោជន៍បាន លុះត្រាតែខ្លួនបានទទួលការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតផ្ទាល់មាត់ក៏ដោយ។ និយមន័យការឆែកឆេរ គ្រប់ការឆែកឆេរសំដៅការរុករកតម្រុយភស្តុតាងក្នុងកន្លែងបិទជិត ដែលអនុញ្ញាតឲ្យកំណត់អត្ថិភាពនៃបទល្មើស ឬ ចង្អុលបង្ហាញចារី ។ នៅពេលធ្វើការឆែកឆេរ ត្រូវមានវត្តមានអ្នកកាន់

---

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០៧ ។
[25] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា៨៩។

កាប់ទីកន្លែង ឬសាក្សីពីរនាក់ដែលមិនមែនជាភ្នាក់ងារស៊ើបអង្កេត (ជាអាទិ៍ នគរបាល ឬកងរាជអាវុធហត្ថ)។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុឆែកឆេរ ដែលមានការអនុញ្ញាតរបស់ព្រះរាជអជ្ញា កាលបរិច្ឆេទ និង ម៉ោងក្នុងការអនុញ្ញាតនោះ។ អត្តសញ្ញាណអ្នកកាន់កាប់ទីកន្លែង ក៏ដូចជាអត្តសញ្ញាណរបស់សាក្សី ក៏ត្រូវចុះនិទ្ទេសផងដែរ។ មន្ត្រីនគរបាលយុត្តិធម៌អាចកាន់កាប់វត្ថុតាងផ្សេងៗ ហើយត្រូវបិទស្លាកអាចមិលក្ខកំបោលើវត្ថុនោះក្រោយពីបានបង្ហាញអ្នកកាន់កាប់ទីកន្លែង ឬសាក្សីមើលរួច។ កំណត់ហេតុចាត់វត្ថុតាងមួយនឹងត្រូវធ្វើឡើងដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ឬហត្ថលេខារបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពពេលវេលាដែលកំណត់ដោយច្បាប់។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរនៅចន្លោះម៉ោង ៦ព្រឹក និងម៉ោង១៨ល្ងាច។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរនៅពេលយប់ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកាលណាមានសម្រែកស្រែកឲ្យជួយពីក្នុងទីកន្លែង ឬ ទីកន្លែងដែលបើកចំហរដល់សាធារណៈជន ឬ កន្លែងបេស្យាកម្ម ឬ កន្លែងដែលបុគ្គលលក់ចែកចាយ ឬ ជក់គ្រឿងញៀន។ គួរកត់សម្គាល់ថាអំណាចឆែកឆេររបស់មន្ត្រីនគរបាលយុត្តិធម៌មានព្រំដែន ដោយមូលហេតុទីកន្លែងដែលខ្លួនចុះធ្វើអន្តរាគមន៍។ ជាអាទិ៍ ក្នុងការឆែកឆេរការិយាល័យមេធាវី ការអនុញ្ញាតរបស់ព្រះរាជ-អាជ្ញា មិនគ្រប់គ្រាន់ទេ មានតែចៅក្រមប៉ុណ្ណោះដែលអាចធ្វើការឆែកឆេរនៅចំពោះមុខប្រធានគណៈមេធាវីតំណាងរបស់ខ្លួន។អាគារសារពត៌មាន សហគ្រាសសារពត៌មានសរសេរ សារពត៌មានសោតទស្សន៍ ក៏ត្រូវបានការពារផងដែរព្រោះការឆែកឆេរ អាចធ្វើទៅបាននៅចំពោះមុខចៅក្រមដើម្បីធានារ៉ាប់រងកុំឲ្យការឆែកឆេរនេះមានផលប៉ះពាល់ដល់ ការប្រកបរបរជាអ្នកសារពត៌មានសេរី បង្កើតជាឧបសគ្គដល់ការផ្សាយពត៌មាន និង ធ្វើអោយយឺតយ៉ាវដល់ការផ្សាយពត៌មានដោយមិនត្រឹមត្រូវ។ បទប្បញ្ញត្តិទាំងអស់នេះត្រូវតែគោរព បើមិនដូច្នេះទេ នឹងនាំអោយមានការមោឃភាពនៃនីតិវិធី[26]។

### ២.២.៣. ការស្តាប់ចម្លើយ

គ្រប់មន្ត្រីនគរបាលយុត្តិធម៌ អាចកោះហៅ និង ស្តាប់ចម្លើយបុគ្គលទាំងឡាយណាដែលអាចផ្តល់ពត៌មានទាក់ទងនឹងអង្គហេតុ[27]។ មន្ត្រីនេះក៏អាចហៅ និងនាំមកកាន់មន្ទីររបស់ខ្លួននៅបុគ្គលគ្រប់រូបដែលបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ដើម្បីធ្វើការស្តាប់ចម្លើយជនទាំងនោះ។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្តាប់ចម្លើយរបស់ជនដែលមិនពាក់ព័ន្ធនឹងអង្គហេតុដូចជា សាក្សី និង ជនរងគ្រោះ និងស្តាប់ចម្លើយជនដែលសង្ស័យ។ ក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង សាក្សីដែលត្រូវបានកោះហៅដោយមន្ត្រីនគរបាលយុត្តិធម៌មាន កាតព្វកិច្ចចូលមកបង្ហាញខ្លួន។ ក្នុងករណី

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១០៩។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៩៥។

រឺងទទឹងសាក្សី អាចត្រូវបានបង្ខំ តាមរយៈសេចក្តីបង្គាប់ឲ្យចូលខ្លួនដែលចេញដោយព្រះរាជអាជ្ញា តាមសំណើររបស់ មន្ត្រីនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌ ទទួលបានអនុញ្ញាតអោយប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំអោយបុគ្គលនោះចូលមកបង្ហាញខ្លួន។ ការស្តាប់ចម្លើយនីមួយៗត្រូវធ្វើកំណត់ហេតុ ដែលដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលគេស្តាប់ចម្លើយ។ បុគ្គលទាំងនេះត្រូវបានគេចុះហត្ថលេខាលើកំណត់ហេតុ បន្ទាប់ពីបានអានឡើងវិញដោយខ្លួនឯង និងអ្នកដទៃ។ បុគ្គលទាំងនេះអាចបដិសេធមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ។ ក្នុងករណីនេះ ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។ ជាចុងក្រោយក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែម្នាក់ដែលការបកប្រែនេះអាចមានសុពលភាពទៅបាន លុះត្រាតែអ្នកបកប្រែបានស្បថទៅតាមជំនឿ និងសាសនារបស់ខ្លួនថានឹងបកប្រែឲ្យបានត្រឹមត្រូវនៅចម្លើយរាយការណ៍។ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសយកពីក្នុងចំណោមអ្នកស៊ើបអង្កេត (កងរាជអាវុធហត្ថ ឬនគរបាល) ឬ ក្នុងចំណោមបុគ្គលដែលពាក់ព័ន្ធក្នុងចំណោមរឿងក្តីជាមួយគ្នាឡើយ ។

### ២.២.៤. ការពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

មាត្រា ៩៥ ចែងថាមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន ដោយសុំជំនួយពីអ្នកជំនាញ ឬ បុគ្គលគ្រប់រូបដែលមានជំនាញ ដែលត្រូវបានស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងជួយដោយភក្តីភាពដល់តុលាការ។ ផ្ទុយទៅវិញមន្ត្រីនគរបាលយុត្តិធម៌ ពុំមានសមត្ថកិច្ចបញ្ជារឲ្យស្តាប់ ឬ ថតការសន្ទនាតាមទូរស័ព្ទ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងគ្នាតាមរយៈមធ្យោបាយទូរគមនាគមន៍ដូចជា សាហ្វាក់ ឬ សារអាំងទែនេត[28] ។

### ២.២.៥. ការឃាត់ខ្លួន

ការឃាត់ខ្លួនដែលមានចែងក្នុងមាត្រា៩៦ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថាដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ឬដែលអាចផ្តល់ពត៌មានស្តីអំពីរឿងរ៉ាវ ប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញជនដែលអាចផ្តល់ពត៌មានត្រូវបានប្រកែកមិនព្រមផ្តល់ ហើយព្រះរាជអាជ្ញាអនុញ្ញាតឲ្យធ្វើការឃាត់ខ្លួនជាលក្ខណ៍អក្សរ។ ការឃាត់ខ្លួនអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌រក្សាទុកនៅក្រោមការចាត់ចែងរក្សារបស់ខ្លួន នៅបុគ្គលទាំងឡាយណាដែលអាចមានសារៈសំខាន់ដល់ការស៊ើបអង្កេត និងការសួរចម្លើយជននោះ។ ដូច្នេះយើងឃើញថាវិធាននេះអាចទាក់ទងនឹងបុគ្គល

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១៥០។

ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬ ជួយឲ្យមានការប្រព្រឹត្តបទល្មើស និងសាក្សី។ វិធានដែលទាក់ទងនឹងការឃាត់ខ្លួនមានលក្ខណៈដាច់ខាត ការមិនគោរពនឹងនាំឲ្យមានមោឃភាពនីតិវិធី។

វិធាននេះជាអំណាចតែមួយគត់របស់មន្ត្រីនគរបាលយុត្តិធម៌ ក្រោមការពិនិត្យផ្ទាល់របស់ព្រះរាជអាជ្ញា។ ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ ដែលបានឃាត់ខ្លួនជនសង្ស័យ ត្រូវរាយការណ៍ភ្លាមជូនទៅព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ធាតុទាំងអស់ ដែលបញ្ជាក់អំពីការឃាត់ខ្លួន បើពុំនោះទេនឹងនាំឲ្យមានការមោឃភាពកិច្ចនីតិវិធី ដូច្នេះការរាយការណ៍នេះពុំអាចពន្យាពេលបានទេ លើកលែងតែមានកាលៈទេសៈពិសេសដែលមិនអាចជំនះបាន។ ដោយសំអាងហេតុផលលើភាពចាំបាច់នៃការស៊ើបអង្កេត ការឃាត់ខ្លួនអាចធ្វើទៅបានក្នុងថិរវេលា៤៨ម៉ោង។ គណៈកម្មការបានតម្លើងថិរវេលានេះ ពី ២៤ម៉ោង ទៅ៤៨ម៉ោង។ ច្បាប់ចុះថ្ងៃទី១០ កក្កដា ឆ្នាំ ២០០២ បានអនុម័តយករយៈពេលនេះ ។ ថិរវេលា៤៨ម៉ោង ជាថិរវេលាអតិបរមារសម្រាប់សាក្សី។ ផ្ទុយទៅវិញ ចំបុគ្គលសង្ស័យការឃាត់ខ្លួនអាចនឹងត្រូវបានពន្យាពេល សម្រាប់ថេរវេលាថ្មី២៤ម៉ោង។ ដូចដែលអត្ថបទនៃក្រមបានរំលឹកស្រាប់ ការពន្យាពេលនេះគឺជាវិធានពិសេស។ ការពន្យាពេលអាចធ្វើទៅបានលុះត្រាតែវាចាំបាច់ចំពោះ ដំណើរការប្រព្រឹត្តទៅដ៏ល្អរបស់ការស៊ើបអង្កេត។ តុលាការកំពូលត្រូវធានាឲ្យបាននៅការគោរពលក្ខខណ្ឌនេះ ការពន្យាពេលនឹងត្រូវធ្វើទៅបានដោយការស្នើរសុំរបស់មន្ត្រីនគរបាល-យុត្តិធម៌ ទៅកាន់ព្រះរាជអាជ្ញា ដើម្បីផ្ទៀងផ្ទាត់មើលមូលកភាព និងអំណៈអំណាងដោយរក្សាឲ្យបាននៅភាពចាំបាច់នៃការស៊ើបអង្កេត។ ការអនុញ្ញាតអោយពន្យាពេលការឃាត់ខ្លួន ត្រូវធ្វើឡើងជាលាយលក្ខអក្សរដោយមានសំអាងហេតុ និង ការដាក់បញ្ចូលក្នុងសំណុំរឿង បើពុំនោះទេនឹងត្រូវចាត់ទុកជាមោឃ។

គ្រប់ការឃាត់ខ្លួនទាំងអស់ត្រូវចុះបញ្ជីកាន់កាប់ ក្នុងកន្លែងនីមួយៗរបស់នគរបាល ឬ អាវុធហត្ថហើយដែលមាននិទ្ទេស [29] ។បញ្ជីនេះត្រូវថែរក្សាក្នុងការគ្រប់គ្រងរបស់អាជ្ញាធរតុលាការជានិច្ច។ ក្រមបានយកចិត្តទុកដាក់ ក្នុងការចែងពីចំណុចចាប់ផ្តើមនៃថិរវេលានៃការឃាត់ខ្លួនដោយចែងថាថិរវេលានេះ ត្រូវគិតពីម៉ោងសួរដេញដោល ឬពីម៉ោងដែលសមីខ្លួនមកដល់មន្ទីនគរបាល ឬកងរាជអាវុធហត្ថ ក្នុងករណីដែលមានការកោះហៅឲ្យចូលមកបង្ហាញខ្លួន។ អត្ថបទច្បាប់មានលក្ខណៈច្បាស់លាស់ជាពិសេស ហើយជាលទ្ធផល ការឃាត់ខ្លួនដែលធ្វើឡើងជាអាទិ៍ បន្ទាប់ពីការស្តាប់ចម្លើយ ត្រូវចាត់ទុកជាមោឃៈ។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១០១។

### ២.២.៦. ចំពោះការឃាត់ខ្លួនសម្រាប់អនីតិជន

មាត្រាដដែលចែងថាចំពោះអនីតិជនដែលមានអាយុតិចជាង១៤ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនទេ។ ម្យ៉ាងទៀតគ្មានការពន្យាណាមួយដែលអាចអនុញ្ញាតឲ្យធ្វើឡើងបានឡើយចំពោះអនីតិជន។ ក្រមនេះចែងថាចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំមិនអាចត្រូវបានគេឃាត់ខ្លួនហួសពី៣៦ម៉ោងបានឡើយ។

ចំពោះបទមជ្ឈិមអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនរយៈពេលហួសពី ២៤ម៉ោងបានឡើយ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៤៨ម៉ោងបានឡើយ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោងបានឡើយ។

អនីតិជនដែលមានអាយុតិចជាង ១៦ឆ្នាំ អាចត្រូវបានគេឃាត់ខ្លួនដោយមិនគិតពីភាពធ្ងន់ធ្ងរនៃបទល្មើសដែលប្រព្រឹត្ត។ ប៉ុន្តែការឃាត់ខ្លួននេះមិនអាចត្រូវឲ្យលើសពី ៤៨ម៉ោង ព្រោះមាត្រា-១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបដិសេធចោលគ្រប់លទ្ធភាពនៃការពន្យាពេល។ ជាចុងក្រោយរបបនៃការឃាត់ខ្លួនអនីតិជនអាយុលើសពី១៦ឆ្នាំ ដូចគ្នានឹងរបបនៃការឃាត់ខ្លួននីតិជនដែរ ។ នៅពេលដែលអនីតិជនត្រូវបានគេឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនពត៌មានគ្រប់មធ្យោបាយដល់ឪពុកម្តាយ តំណាងស្របច្បាប់ ឬអ្នកទទួលបន្ទុកលើអនីតិជននោះ [30]។

### ២.២.៧. ការធានាក្នុងការឃាត់ខ្លួន

ការធានាមួយក្នុងចំណោមការធានាសំខាន់បំផុត ស្ថិតនៅត្រង់កាតព្វកិច្ចដែលយើងបានលើកឡើងខាងលើ របស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការផ្តល់ពត៌មានភ្លាមៗ ទៅឲ្យព្រះរាជអាជ្ញា និងស្ថិតត្រង់ការបញ្ជូនឯកសារ និង ភស្តុតាងដែលបញ្ជាក់អំពីការឃាត់ខ្លួន។ ប្រសិទ្ធិភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវផ្អែកទៅលើកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការតាក់តែងកំណត់ហេតុស្តីពីការឃាត់ខ្លួន។ មាត្រា ៩៧ចែងថាកំណត់ហេតុត្រូវមានការចុះសេចក្តីដូចតទៅ បើពុំនោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី៖

- ឈ្មោះ និង ឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានបង្គាប់ឲ្យឃាត់ខ្លួន ។
- អត្តសញ្ញាណឈ្មោះ និង អាយុរបស់បុគ្គលដែលត្រូវឃាត់ខ្លួន ។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១០០។

- មូលហេតុនៃការឃាត់ខ្លួន ។
- ថ្ងៃ និង ម៉ោងដែលផ្ដើមឃាត់ខ្លួន ។
- ការឲ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តក្នុងមាត្រា ៩៨ ។
- ឈ្មោះអ្នកបកប្រែប្រសិនបើមាន ។

កំណត់ហេតុត្រូវចុះហត្ថលេខាបុគ្គលដែលឃាត់ខ្លួន។ បើជននោះបដិសេធមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសអំពីការបដិសេធនេះ។ ម្យ៉ាងទៀតកំណត់ហេតុសង្ខេបស្ដីពីការឃាត់ខ្លួន ត្រូវភ្ជាប់ជាមួយនីតិវិធីដែល ក្រៅពីចុះនិទ្ទេសដែលបានរៀបរាប់ខាងលើ មានចុះបែបបទនៃការផ្ដល់ពត៌មានទៅព្រះរាជអាជ្ញា និងបែបបទនៃការឲ្យដំណឹងដល់ឪពុកម្ដាយ តំណាងស្របច្បាប់ ឬ បុគ្គលដែលទទួលបន្ទុកអនីតិជន ក្នុងករណីដែលអនីតិជនត្រូវគេឃាត់ខ្លួន។ ក្នុងកំណត់ហេតុក៏ត្រូវមានចុះគ្រប់កិច្ចដែលបំពេញ ក្នុងអំឡុងពេលឃាត់ខ្លួន ការពិនិត្យរបស់គ្រូពេទ្យ ការជួបជាមួយមេធាវី ឬ ជនណាម្នាក់ ការពន្យាពេល ព្រមជាមួយនឹងឈ្មោះចៅក្រមដែលបានអនុញ្ញាតឲ្យមាន ការពន្យាពេល រយៈពេលស្ដាប់ចម្លើយនីមួយៗ កាលបរិច្ឆេទ និង ម៉ោងនៃការបញ្ចប់ការឃាត់ខ្លួន និង ឧប្បត្តិហេតុជាយថាហេតុនានា ។

ក្រៅពីនេះចាប់តាំងពីពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឲ្យដឹងអំពីមូលហេតុដែលសម្រេចធ្វើការឃាត់ខ្លួននេះ ដូច្នេះការឲ្យដំណឹងយឺតយ៉ាវនឹងបណ្ដាលឲ្យមានមោឃៈភាពនៃគ្រប់លិខិតទាំងអស់ ដែលបានតាក់តែងក្នុងអំឡុងពេលឃាត់ខ្លួន លើកលែងតែមានទេសកាលពុំអាចជំនះបាន។ ឧទាហរណ៍: ផលលំបាកក្នុងការរកអ្នកបកប្រែភាសាដោយឡែក ឬ ករណីជននោះពុំអាចយល់ពីអានុភាពនៃការឲ្យដំណឹង។ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវឲ្យដំណឹងដល់មន្ត្រីនគរបាលដែលឃាត់ខ្លួន ក្នុងភាសាដែលជននោះអាចយល់អំពីសិទ្ធិរបស់ខ្លួនដូចជា ៖

➢ ជនដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬ ជាមួយអ្នកណាម្នាក់ដែលខ្លួនជ្រើសរើស កុំឲ្យតែជននេះមានការទាក់ទិនក្នុងរឿងជាមួយគ្នា ចាប់ពីម៉ោងទី២៥ (ក្នុងរយៈពេល ២៤ម៉ោងបានកន្លងផុត)។ បុគ្គលដែលបានជ្រើសរើសត្រូវទទួលពត៌មានភ្លាមៗអំពីការស្នើរសុំនេះតាមគ្រប់មធ្យោបាយ។ ការសន្ទនាធ្វើឡើងដោយការសំងាត់ ដើម្បីធានានូវការសំងាត់ និង មិនត្រូវលើសពី ៣០ នាទី។ ក្រោយការសន្ទនាបុគ្គលដែលបានទទួលពិគ្រោះយោបល់អាចធ្វើកំណត់សម្គាល់ជាលាយល័ក្ខអក្សរដែលត្រូវភ្ជាប់មកក្នុងនីតិវិធី។ កម្មវត្ថុនៃការពិនិត្យពិគ្រោះនេះគឺ ត្រូវផ្ទៀងផ្ទាត់មើលថាតើស្ថានភាពសុខភាពរបស់ជននេះសមស្របនឹងវិធានឃាត់ខ្លួនដែរ ឬ ទេ? គ្រូពេទ្យចេញវិញ្ញាបនបត្របញ្ជាក់សុខភាព។ បើគ្រូពេទ្យគិតថាស្ថានភាពសុខភាពមិនសមស្រប និង វិធានឃាត់ខ្លួនមន្ត្រី

នគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា។ វិញ្ញាបនបត្របញ្ជាក់សុខភាព ត្រូវភ្ជាប់នឹងនីតិវិធីដែលមានភ្ជាប់នឹងកំណត់ហេតុដែលចុះនិទ្ទេស អំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ និង ម៉ោងនៃការពិនិត្យ។ ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន។

នៅពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលពាក់ព័ន្ធត្រូវបញ្ជូនទៅព្រះរាជអាជ្ញាភ្លាម។ សេចក្តីព្រៀងចែងថាការបង្ហាញខ្លួននេះ ត្រូវធ្វើក្នុងចិរវេលា ដែលលឿនបំផុត។ បន្ទាប់ពីកំណែប្រែ មាត្រា ១០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ក្នុងករណីដែលពុំអាចគោរពតាមចិរវេលាដែលបានកំណត់ ដោយមូលហេតុពិសេស បណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬបណ្តាលមកពីចម្ងាយផ្លូវឆ្ងាយ គេអាចបន្តបន្ថែមបាននៅពេលវេលាចាំបាច់សម្រេចដឹក ជនឃាត់ខ្លួននេះទៅ ជូនព្រះរាជ-អាជ្ញា តាមមធ្យោបាយយ៉ាងឆាប់រហ័សដែលអាចធ្វើទៅបាន។ មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុដែលប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។

# ជំពូកទី៣
# ការប្រៀបធៀបស៊ើបអង្កេតជាក់ស្តែង និង ស៊ើបអង្កេតបឋម

ដើម្បីបង្ហាញអោយឃើញពីភាពខុសប្លែកគ្នា នឹងភាពស្របគ្នាក្នុងកិច្ចស៊ើបអង្កេតបឋម និង ការស៊ើបអង្កេតជាក់ស្តែង ក្នុងគោលបំណងអនុវត្តយ៉ាងណាកុំអោយមានភាពរំលោភបំពានដល់សិទ្ធិពលរដ្ឋដែលត្រូវបានការពារដោយច្បាប់ ទោះបីជាក្នុងស្ថានភាពណាក៏ដោយ មិនថាក្នុងគោល-ដៅស៊ើបអង្កេត ដើម្បីស្វែងរកបទល្មើសក្នុងន័យស្វែងរកអោយឃើញអ្នកបានរំលោភច្បាប់ព្រហ្ម-ទណ្ឌជាធរមានយ៉ាងណាក្តី ក៏អ្នកអនុវត្តនិងអ្នកសុំអោយអនុវត្តមិនត្រូវអនុវត្តកិច្ចការរបស់ខ្លួនក្នុងការស៊ើបអង្កេតបំពានទៅលើពលរដ្ឋណាម្នាក់ដោយមិនត្រឹមត្រូវដែរ។ ហេតុដូច្នេះហើយបុគ្គលដែលទទួលបានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត ត្រូវគោរពអោយបាននូវបញ្ញត្តិច្បាប់និងញែកអោយដាច់ពីកិច្ចក្នុងការស៊ើបអង្កេតជាក់ស្តែងនិងការស៊ើបអង្កេតបឋម ថាតើមានលក្ខណៈខុសគ្នា និង មានលក្ខណៈដូចគ្នាត្រង់ចំណុចណាខ្លះ?

## ផ្នែកទី១ ចំណុចដូចគ្នាក្នុងការស៊ើបអង្កេត

យ៉ាងណាមិញបញ្ញត្តិនៅក្នុងការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតជាក់ស្តែងមានលក្ខ-ណៈដូចគ្នានូវចំណុចជាច្រើនដូចជាបុគ្គលដែលអនុវត្តកិច្ចនីតិវិធី និង នីតិវិធីក្នុងការស៊ើបអង្កេតព្រមទាំងចំណុចដូចគ្នាក្នុងបញ្ញត្តិមោឃៈភាព ជាមួយនឹងភាពដូចគ្នានៅក្នុងលក្ខណៈប្រគល់វត្ថុចាប់យកជាអាទ៍។

### ១.១. បុគ្គលអនុវត្តកិច្ចនីតិវិធី

ចំពោះដំណើរការក្នុងការស៊ើបអង្កេតនេះ មិនអាចអនុវត្តទៅបានទេបើពុំមានសមាសភាពអ្នកស៊ើបអង្កេតពោល គឺបុគ្គលទាំងឡាយដែលទទួលបានសិទ្ធិអំណាចក្នុងការស៊ើបអង្កេតដោយបញ្ញត្តិច្បាប់។ យ៉ាងណាមិញដំណើរការប្រព្រឹត្តទៅនៃការស៊ើបអង្កេតជាក់ស្តែងច្បាប់បានផ្តល់សិទ្ធិអំណាចនេះដល់នគរបាលយុត្តិធម៌ ក្រោមការសម្របសម្រួលពីព្រះរាជអាជ្ញាក្នុងកិច្ចស៊ើបអង្កេតដូចជាវិធានការស្រាវជ្រាវក្នុងការឆែកឆេរបទល្មើសជាក់ស្តែង ដើម្បីចាប់យកវត្ថុតាងដែលសកម្មភាពទាំងអស់នេះធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ក្រោមការបញ្ជាផ្ទាល់ដោយព្រះរាជអាជ្ញា ពោលគឺសមាសភាពអ្នកស៊ើបអង្កេតជាក់ស្តែងមានព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌ ចំណែកឯការស៊ើបអង្កេតបឋមវិញមានសមាសភាពអ្នកស៊ើបអង្កេតដូចគ្នាទៅនឹងការស៊ើបអង្កេតជាក់ស្តែងដែរ។ ត្រង់ចំណុចនេះហើយដែលបញ្ជាក់ថាមានលក្ខណៈដូចគ្នាចំពោះបុគ្គលដែលស៊ើបអង្កេត ពីព្រោះច្បាប់មិនបានផ្លាស់ប្តូរសមាសភាពបុគ្គលដែលមានសិទ្ធិស៊ើបអង្កេតបឋម ឬជាក់ស្តែងនោះទេ។

### ១.២. នីតិវិធីក្នុងការស៊ើបអង្កេត

ដើម្បីកំណត់ទៅបានអំពីបទល្មើសព្រហ្មទណ្ឌ និង ការស្វែងរកអោយឃើញពីពិរុទ្ធភាពនៃជនល្មើស ច្បាប់បានកំណត់នីតិវិធីជាច្រើនក្នុងគោលបំណង ឲ្យអ្នកមានសិទ្ធិអំណាចស៊ើបអង្កេតគោរពនិងប្រតិបត្តិតាម ធ្វើយ៉ាងណាកុំអោយបំពានលើទ្រព្យសម្បត្តិ និងព្រមទាំងសិទ្ធិជារូបវន្តរបស់បុគ្គលជាដាច់ខាតរបស់ពលរដ្ឋដែលជាសមាជិកក្នុងសង្គម។ ចំពោះបញ្ញត្តិដែលទាក់ទងនឹងកិច្ចនីតិវិធីទាំងអស់សុទ្ធសឹងតែបានគិតពីផលប្រយោជន៍សង្គមជាធំ គួរយ៉ាងក្នុងដំណើរការឃាត់ខ្លួននិងបញ្ជូនខ្លួនដែលជាកិច្ចនីតិវិធីស៊ើបអង្កេតជាក់ស្តែង មានគោលបំណងការពារមិនអោយជនណាម្នាក់ដែលគេសង្ស័យពាក់ព័ន្ធនឹងបទល្មើស ព្រមទាំងធ្វើយ៉ាងណាកុំអោយជននោះមានលទ្ធភាពទៅបំផ្លាញ់ភស្តុតាង ឬ ទៅគំរាមគំហែងសាក្សីនិងជនរងគ្រោះ។ ម្យ៉ាងទៀតងាយស្រួលក្នុងការសាកសួរយកចម្លើយដើម្បីកសាងសំណុំរឿងបញ្ជូនតុលាការ។ គួរអោយកត់សម្គាល់ផងដែលថា ការឃាត់ខ្លួន ឬការបញ្ជូនខ្លួនខាងលើចំពោះបុគ្គល ដែលមិនទាន់មានទោសសោះក្នុងគោលបំណងស្វែងរកអោយឃើញពីភាពសង្ស័យថាបានចូលរួម ឬ បុគ្គលដែលបានដឹងពីបទល្មើស ដែលបានព្យាយាមលាក់ ពតិមានមិនផ្តល់ពតិមានដល់សមត្ថកិច្ច[31]ចំណែកឯការឃាត់ខ្លួន ឬ ការបញ្ជូនខ្លួនចំពោះករណីការស៊ើបអង្កេតបឋមទាក់ទងទៅនឹងបទឧក្រិដ្ឋ ឬ បទមជ្ឈិមអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញត្តិស្តីពីការឃាត់ខ្លួននិងការបញ្ជូនខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង [32] ។ លក្ខណៈបែបនេះហើយធ្វើអោយយើងកត់សម្គាល់បានថាមានភាពដូចគ្នា ចំពោះបញ្ញតិស្តីពីការឃាត់ខ្លួនជំពូកទី៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងជំពូកទី៤ស្តីពីការបញ្ជូនខ្លួន នៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងការស៊ើបអង្កេតជាក់ស្តែងក៏អាចទៅអនុវត្តចំពោះករណីការស៊ើបអង្កេតបឋមបានដែរ នេះអាចបញ្ជាក់បានថាមានលក្ខណៈដូចគ្នារវាងនីតិវិធីស៊ើបអង្កេតបឋម និង ការស៊ើបអង្កេតជាក់ស្តែង។

#### ១.២.១. បញ្ញត្តិទូទៅ

ចំពោះវិធានការស្រាវជ្រាវមួយចំនួនដែលមានលក្ខណៈដូចគ្នា ទៅលើការអនុវត្តកិច្ចស៊ើបអង្កេត។ វិធានដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការស៊ើបអង្កេតបឋមមានបទប្បញ្ញត្តិស្តីពីកំណត់ហេតុការស្រាវជ្រាវ និងការពិនិត្យ [33] មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និង ការពិនិត្យរបស់ខ្លួនចំពោះករណីការស៊ើបអង្កេតជាក់ស្តែងនិងការស៊ើបអង្កេតបឋម។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា៩៦។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១១៦។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា៩០។

ម្យ៉ាងទៀតបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ[34] ក៏ត្រូវយកទៅអនុវត្តដូចគ្នាផងដែរ ចំពោះការស៊ើបអង្កេតបឋមនិងការស៊ើបអង្កេតជាក់ស្តែង ពោលគឺអ្នកជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រត្រូវបានបង្កើតឡើងអោយមានបញ្ជីថ្នាក់ជាតិអ្នកជំនាញដែលត្រូវរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយអ្នកជំនាញត្រូវបំពេញលក្ខខណ្ឌដូចក្នុងមាត្រា១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែបើមិនអាចបង្អង់រង់ចាំធ្វើការពិនិត្យបច្ចេកទេស ឬអ្នកវិទ្យាសាស្ត្របានទេ នគរបាលយុត្តិធម៌ពឹងបុគ្គលគ្រប់រូបដែលមានមុខជំនាញតែពុំទាន់មានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិបាន។ យ៉ាងណាមិញ វិធានហាមឃាត់ចំពោះមន្ត្រីនគរបាលយុត្តិធម៌ មិនអនុញ្ញាតឲ្យបង្គាប់ឲ្យស្តាប់ និងថតសំឡេងសន្ទនាតាមទូរសព្ទ័ និងពុំមានអំណាចបង្គាប់ឲ្យចាប់ និង ថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមន៍ជាអាទិ៍ សារតាមទូរសារ ឬ សារតាមអ៊ិនធើណែតឡើយ ពីព្រោះសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ប៉ុន្តែត្រូវលើកលែងបទប្បញ្ញត្តិពិសេសមួយចំនួនដែលអនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិនេះ គួរយ៉ាងដូចជា មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ និងមន្ត្រីនគរបាលយុត្តិធម៌ដែលប្រឆាំងទៅនឹងបទល្មើសចោរកម្ម ឬ ឧក្រិដ្ឋកម្មអន្តរជាតិ ជាដើម។ គួរឲ្យកត់សម្គាល់ផងដែរថា បទប្បញ្ញត្តិស្តីពីការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍[35]នេះត្រូវយកទៅអនុវត្តដូចគ្នាចំពោះការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតជាក់ស្តែង ពោលគឺសបញ្ជាក់អោយឃើញថាមានលក្ខណៈដូចគ្នារវាងការស៊ើបអង្កេតបឋម និងស៊ើបអង្កេតជាក់ស្តែង។ មួយវិញទៀត វិធានការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា[36] ដើម្បីធ្វើការចោទប្រកាន់ ឬកិច្ចនីតិវិធីបន្ត និងបទប្បញ្ញត្តិស្តី និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ[37] នៃក្រមនេះត្រូវយកមកអនុវត្តក្នុងការស៊ើបអង្កេតបឋម[38]។

### ១.២.២. បញ្ញត្តិដោយឡែក

ចំពោះបទប្បញ្ញត្តិដោយឡែកមួយចំនួនផងដែរ ក៏បានកំណត់អំពីការផ្តល់ជាជំនឿទុកចិត្តដល់នគរបាលយុត្តិក្នុងការអនុវត្ត ប្រើប្រាស់វិធានការស្រាវជ្រាវប្រមូលនូវភស្តុតាង និងស្វែងរកឲ្យឃើញពីពិរុទ្ធភាពនៃជនល្មើស ដើម្បីធ្វើជាកំណត់ហេតុបញ្ជូនទៅកាន់តុលាការ។ ហើយតាមគោលការណ៍កំណត់ហេតុមានតម្លៃត្រឹមតែជាព័ត៌មានប៉ុណ្ណោះ ពោលគឺកំណត់ហេតុនោះធ្វើឡើងដោយភ្នាក់ងារ

---

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា៩៥។

[35]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១០៥។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១០៧។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១០៨។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១១២។

មន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែចំពោះកំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌វិញ ច្បាប់បានសន្មត់ថាជាភស្តុតាងបន្ទាល់[39] មានន័យថាជាឯកសារដើម ហើយត្រូវទុកជាឯកសារជឿរហូតដល់មានភស្តុតាងផ្ទុយ។ ម្យ៉ាងវិញទៀត ភស្តុតាងផ្ទុយនេះអាចដាក់បានក្នុងគោលបំណងបដិសេធចោលនូវឯកសារ ដែលទុកជាបន្ទាល់នោះ អាចដាក់ជូនមកចៅក្រមតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ចៅក្រមត្រូវធ្វើមូលវិចារណ៍ដោយសេរីលើកំណត់ហេតុ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម។ ចំពោះមូលដែលឡើងដោយចៅក្រមនេះ គាត់មានសិទ្ធិអំណាចក្នុងជឿ ឬ មិនជឿតាមឆន្ទានុសិទ្ធិរបស់គាត់ដោយផ្អែកតាមភស្តុ-តាងដែលបានដាក់ជូននោះ។ គួរឲ្យកត់សម្គាល់ផងដែរថា ចំពោះអំណាចធ្វើមូលវិចារទៅលើកំណត់ហេតុ ដែលត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌របស់ចៅក្រមក្នុងក្របខ័ណ្ឌនៃការស៊ើប-អង្កេតជាក់ស្តែងក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអំណាចធ្វើមូលវិចារណ៍របស់ចៅក្រម ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម។ លក្ខណៈបែបនេះហើយ អាចកំណត់បានថាមានចំណុចដូចគ្នារវាងការស៊ើបអង្កេតបឋម និងស៊ើបអង្កេតជាក់ស្តែង។

មួយវិញទៀត ភាពដូចគ្នារវាងការស៊ើបអង្កេតជាក់ស្តែង និងស៊ើបអង្កេតបឋមកើតមានផងដែរ ចំពោះការឃាត់ខ្លួនជនសង្ស័យករណីការស៊ើបអង្កេតបឋម ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម នោះបទប្បញ្ញត្តិនៃជំពូកទី៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី៤ ស្តីអំពីការបញ្ជូនខ្លួននៃមាតិកាទី២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងក្នុងគន្លីនេះ ត្រូវយកមកអនុវត្ត[40]។

### ១.២.៣. ការមោឃភាពក្នុងបញ្ញត្តិទូទៅ

ដើម្បីការពារទៅលើផលប្រយោជន៍របស់ពលរដ្ឋ និង ធ្វើយ៉ាងណាដើម្បីឲ្យបុគ្គលដែលមានសិទ្ធិអំណាច ក្នុងការស៊ើបសង្កេតនេះ ដូចជាព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលស៊ើបសួរ ធ្វើការប្រតិបត្តិឲ្យម៉ត់ចត់ គោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមានដែលមានគោលបំណងការពារទៅលើសិទ្ធិបុគ្គល និងសណ្តាប់ធ្នាប់សង្គម។ បើអ្នកដែលមានសិទ្ធិអំណាចអនុវត្តផ្ទុយពីបទប្បញ្ញត្តិដែលមានចែងស្តីពីកិច្ចស៊ើបអង្កេតនេះ ច្បាប់ក៏បានឆ្លើយតបដោយប្រើវិធានការមោឃភាពក្នុងក្របខ័ណ្ឌ បទល្មើសជាក់ស្តែងត្រូវមានលក្ខណៈដាច់ខាតដែលត្រូវគោរព បើមិនដូច្នេះទេ និងនាំឲ្យមោឃនៃនីតិវិធីនេះ[41] ចំណែកឯការមិនគោរពវិធានក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋមវិញ គឺ

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១១០។
[40] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១១៦។
[41] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០៩។

មានលក្ខណៈដូចគ្នានូវប្បញ្ញត្តិមួយចំនួនដែលមិនគោរពវិធាន និងទម្រង់ដូចជាការឃាត់ខ្លួន [42] កំណត់ហេតុស្តីពីការឃាត់ខ្លួន [43] ព្រមទាំងអនីតិជនដែលត្រូវបានឃាត់ខ្លួន [44] និងការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯងជាអាទិ៍ [45] ត្រូវមានលក្ខណៈដាច់ខាតត្រូវគោរពបើមិនដូច្នេះទេនាំឲ្យមានមោឃភាពទាំងក្នុងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម[46]។ ដូចនេះ ការមោឃភាពចំពោះកិច្ចនីតិវិធីស៊ើបអង្កេត ដូចបានរៀបរាប់ខាងគឺមានលក្ខណៈដូចគ្នាត្រង់ចំណុចដែលបានរៀបរាប់ខាងលើ។

### **១.២.៤. ការប្រគល់វត្ថុចាប់យក**

ការប្រគល់ឲ្យម្ចាស់ដើមវិញនូវវត្ថុចាប់យកក្នុងក្របខ័ណ្ឌការស៊ើបអង្កេត អាជ្ញាធរដែលមានសមត្ថកិច្ចត្រូវប្រគល់ជូន ឬបង្គាប់ឲ្យប្រគល់ជូនដល់ម្ចាស់ដើមវិញ។ ចំពោះព្រះរាជអាជ្ញាមានសមត្ថ-កិច្ចបង្គាប់ឲ្យប្រគល់វត្ថុដែលបានចាប់បាននៅពេលធ្វើកាស៊ើបអង្កេតទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសម្តែងការពិត ឬជាភស្តុតាងដើម្បីបញ្ជាក់អំពីពិរុទ្ធភាពនៃជនល្មើសទេនោះ ហើយប្រសិនបើកម្មសិទ្ធិនៃវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេពោលគឺគ្មានការជំទាល់អ្វីប្រាកដប្រជាចំពោះកម្មសិទ្ធិវត្ថុនោះទេ ព្រះរាជអាជ្ញាត្រូវបង្គាប់អោយមន្ត្រីនគរបាលយុត្តិធម៌ប្រគល់វត្ថុចាប់យកទាំងនោះទៅកម្មសិទ្ធិដើមវិញ។ ប៉ុន្តែវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិ ដូចជាអាវុធ ឬ ជាតិផ្ទុះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់មិនអាចប្រគល់អោយវិញបានទេ។ វត្ថុទាំងនេះត្រូវរឹបអូស ទុកជាសម្បត្តិរដ្ឋ ឬ ត្រូវបំផ្លាញចោល[47]។ ម្យ៉ាងវិញទៀត ក្នុងករណីព្រះរាជអាជ្ញាមិនព្រមបង្គាប់អោយប្រគល់ ឬ មន្ត្រីនគរបាលយុត្តិធម៌មិនព្រមប្រគល់អោយវិញទេ ម្ចាស់ដើមនៃវត្ថុចាប់យកអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ដើម្បីផ្តល់ជូនអោយអគ្គព្រះរាជអាជ្ញាធ្វើការពិចារណានិងវិនិច្ឆ័យថា យល់ស្របតាមព្រះរាជអាជ្ញាយល់ស្របតាមការទាមទាររបស់ម្ចាស់ដើម បើអគ្គព្រះរាជអាជ្ញាយល់ស្របតាមការទាមទាររបស់ម្ចាស់ដើមនោះ អគ្គព្រះរាជអាជ្ញាត្រូវធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់អោយមន្ត្រី-នគរបាលយុត្តិធម៌ធ្វើការ ប្រគល់វត្ថុជូនម្ចាស់ដើមវិញ ប៉ុន្តែប្រសិនបើអគ្គព្រះរាជអាជ្ញាមិនយល់ព្រមតាមការទាមទារទេនោះ ព្រះរាជអាជ្ញានូវតែមានសមត្ថកិច្ចរក្សាទុកវត្ថុចាប់យករហូតចប់កិច្ចនីតិវិធី។ ផ្ទុយ

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៩៦។
[43] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៩៧។
[44] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០០។
[45] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០៥។
[46] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១១៧។
[47] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១១៩ ។

ទៅវិញប្រសិនបើនីតិវិធីនៅក្នុងដំណាក់ការថៅក្រមស៊ើប ឬដំណាក់ថៅក្រមជំនុំជម្រះហើយនោះ ព្រះរាជអាជ្ញានិងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេកាលណាមានការចោទប្រកាន់ធ្វើនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តិការជំនុំជម្រះ ពោលគឺជាចំណាត់ការស៊ើបសួររបស់ថៅក្រម ឬចំណាត់ការជំនុំជម្រះពោលគឺជាដំណាក់កាលស៊ើបសួររបស់ថៅក្រម ឬ ចំណាក់ការជំនុំជម្រះ ព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញាមិនមានសមត្ថកិច្ចក្នុងការធ្វើការប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញទេ ពីព្រោះវត្ថុចាប់នោះស្ថិតនៅក្នុងដៃថៅក្រមស៊ើបសួរ ឬ ថៅក្រមកជំនុំជម្រះទៅហើយ ដែលជាយុត្តាធិការបន្តបន្ទាប់នៃកិច្ចនីតិវិធិព្រហ្មទណ្ឌ ប៉ុន្តែ កាលបើតុលាការដែលទទួលពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗដើម្បីសម្រេចដោយឯកឯង លើពាក្យសុំអោយមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំនាស់អ្វីជាប្រាកដប្រជាទេ [48] ។ បានសេចក្តីថាប្រសិនបើថៅក្រមស៊ើបសួរ និង ថៅក្រមជំនុំជម្រះមិនបានសម្រេចប្រគល់វត្ថុចាប់យកឲ្យទៅអ្នកមានប្រយោជន៍វិញទេនោះ ដោយមូលហេតុភ្លេចសម្រេចប្រគល់វត្ថុចាប់យកប្រការណាមួយ អ្នកមានប្រយោជន៍អាចដាក់ពាក្យទៅព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា ដើម្បីទទួលបានវត្ថុចាប់យកវិញបាន ពីព្រោះក្រោយពេលបិទបញ្ចប់កិច្ចនីតិវិធីស៊ើបសួរ និងកិច្ចនីតិវិធីជំនុំជម្រះហើយសមត្ថកិច្ចអនុវត្តសេចក្តីសម្រេចបន្ទាប់គឺធ្លាក់លើព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញា។ ដូច្នេះហើយ អ្នកមានប្រយោជន៍ត្រូវប្តឹងទៅព្រះរាជអាជ្ញា។

## ផ្នែកទី២ ចំណុចខុសគ្នានូវវិធាននៃការស៊ើបអង្កេត

### ២.១. ការបើកការស៊ើបអង្កេតបឋម និងជាក់ស្តែង

គោលបំណងនៃកាបែកចែងលក្ខណៈខុសគ្នារវាងការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតជាក់ស្តែងមានចំណុចខុសគ្នាជាច្រើនគួរអោយកត់សម្គាល់ផងដែរ ចំពោះការស៊ើបអង្កេតជាក់ស្តែង គឺមានភាពបន្ទាន់ ដែលតម្រូវឲ្យប្រមូលភស្តុតាងដែលនៅមាននៅឡើយ របស់បទល្មើសដែលទើបប្រព្រឹត្តថ្មីៗ ហើយរូបភាពដែលមានលក្ខណៈជាក់ស្តែងនេះត្រូវបានច្បាប់កំណត់ដូចជា បទល្មើសដែលកំពុងតែប្រព្រឹត្ត និងបទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាម[49]។ ម្យ៉ាងវិញទៀតក៏ត្រូវបានចាត់ទុក

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១២០។
[49] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨៦។

ថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណាក្រោយពេលប្រព្រឹត្តរួចបន្តិចមក ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកីង ឡោមព័ន្ធ និងបុគ្គលដែលត្រូវបានគេឃើញមានវត្ថុ ឬ តម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ពោលគឺដោយកត់សម្គាល់ដោយមើលទៅលើភស្តុតាងបន្សល់ទុក ព្រមទាំងប្រសិនបើនាទីកន្លែងកើតហេតុមិនទាន់ត្រូវបានប៉ះពាល់ណាមួយ ដែលនាំឲ្យបាត់បង់នូវតម្រុយភស្តុតាង[50]។ ឧទាហរណ៍ៈ ចោរគាស់ផ្ទះ ដែលគ្មានអ្នកដឹងហើយបន្សល់ទុកនូវភស្តុតាង ដែលមិនទាន់ត្រូវបានគេបំផ្លិចបំផ្លាញ និងត្រូវបានអ្នកកាប់នៅទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីនេះ ត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។ ចំណែកឯការស៊ើបអង្កេតបឋមវិញ[51] គឺជាស្ថានភាពទាំងឡាយផ្ទុយពីការស៊ើបអង្កេតជាក់ស្តែង ដូចបានរៀបរាប់ខាងលើ។ ម្យ៉ាងវិញទៀត ការស៊ើបអង្កេតបឋមអាចដំណើរការទៅបានដោយការផ្តួចផ្តើមដោយមន្ត្រីនគរបាលយុត្តិធម៌ ឬតាមការសុំរបស់ព្រះរាជអាជ្ញាក្នុងករណីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ[52]។

លក្ខណៈខុសគ្នាម្យ៉ាងទៀត ដែលធ្វើឲ្យងាយស្រួលក្នុងការចែងដាច់ រវាងការស៊ើបអង្កេតទាំងពីរនេះ គឺចំពោះការស៊ើបជាក់ស្តែង ធ្វើឡើងតែនៅក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមប៉ុណ្ណោះរីឯការស៊ើបអង្កេតបឋមវិញ អាចធ្វើចំពោះករណីទាំងអស់ មិនថាបទឧក្រិដ្ឋ មជ្ឈិម ឬលហុនោះទេ។

### ២.២. ថិរវេលាក្នុងការស៊ើបអង្កេត

ចំពោះថិរវេលាក្នុងការឆែកឆេរ បទល្មើសជាក់ស្តែងនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានគ្រប់ពេលវេលា ពោលគឺអាចចូលឆែកឆេរ ២៤ម៉ោង លើ២៤ម៉ោង មិនថាពេលយប់ឬថ្ងៃទេ។ ក្នុងករណីបទល្មើសជាក់ស្តែងអនុលោមតាមមាត្រា៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ នគរបាលយុត្តិធម៌អាចផ្តួចផ្តើមបើកកាស៊ើបអង្កេតលើករណីដូចជា មានសម្រែកឲ្យជួយពីខាងក្នុងទីកន្លែង ឬក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងម៉ោងដែលបើចំហដល់សាធារណជន និងនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ករណីនេះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញាទោះបីជា ការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ [53] ។ ម្យ៉ាងវិញទៀត ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី៧ថ្ងៃឡើយ គិតចាប់ពី

---

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៨៨។

[51] មាត្រា ១១។ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[52] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រចារ្យចាំង ស៊ីណាត។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៩។

ថ្ងៃប្រព្រឹត្តបទល្មើស ប៉ុន្តែ ប្រសិនបើក្នុងករណីការស្រាវជ្រាវចំណាយរយៈពេល៧ថ្ងៃហើយ កិច្ចស៊ើបអង្កេតត្រូវបានប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងចិរវេលានេះ ។ ប្រសិនបើការស៊ើបអង្កេត មិនបានបញ្ចប់ក្នុងរយៈពេល៧ថ្ងៃទេនោះ ពោលបើមន្ត្រីនគរបាលយុត្តិចងបន្តការស្រាវជ្រាវរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធមិត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា[54] ដើម្បីបន្ថែមនូវចិរវេលាក្នុងការស៊ើបអង្កេតបាន តែក្រោមក្របខ័ណ្ឌការស៊ើបអង្កតបឋមវិញ ចំណែកឯការស៊ើបអង្កេតបឋមវិញ មិនមានបានកំណត់ចំនួនប៉ុន្មានថ្ងៃនោះទេ តែបានបញ្ញត្តពីការបើប្រតិបត្តិការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មិនអាចឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ។ ពោលគឺ មន្ត្រីនគរបាលយុត្តិធម៌មិនអាចបើកប្រតិបត្តិការឆែកឆេរបទល្មើសបឋម នៅមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាច បានឡើយ ប៉ុន្តែបើក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌បើកប្រតិបត្តិការឆែកឆេរក្រោយម៉ោង ៦ព្រឹក រហូតដល់ម៉ោង ខ១៨ល្ងាចហើយនៅតែមិនទាន់ចប់កិច្ចនីតិវិធីទៀតនោះ មន្ត្រីនគរបាលយុត្តិធម៌នៅតែបន្តការឆែកឆេររបស់ខ្លួនបាន ទោះក្រោយម៉ោង ១៨ល្ងាចក៏ដោយ [55]។

**ឧទាហរណ៍:** មន្ត្រីនគរបាលយុត្តិធម៌បើកការឆែកឆេរ ផ្ទះរបស់បុគ្គលឈ្មោះ **ក** ក្នុងក្របខណ្ឌការស៊ើបអង្កេតបឋមនៅម៉ោង ១៤រសៀល ប៉ុន្តែការឆែកឆេររហូតដល់ ១៨ល្ងាចហើយ មន្ត្រីនគរបាលយុត្តិធម៌នៅតែមិនទាន់ស្រាវជ្រាវគ្រប់ជ្រុងជ្រោយនៅឡើយ នោះមន្ត្រីនគរបាលយុត្តិធម៌នៅបន្តការឆែកឆេរទៅលើផ្ទះ **ក** ទៀតបាន។

### ២.៣ ការឆែកឆេរ

ការឆែកឆេរនេះដែរ គឺធ្វើឡើងក្នុងគោលបំណងចាប់យកវត្ថុតាងដែលជាប់ទាក់ទងនឹងបទល្មើស។ ចំពោះការឆែកឆេរក្នុងករណីស៊ើបអង្កេតបទល្មើសទាំងពីរ មានលក្ខណៈខុសគ្នាដាច់ចេញពីគ្នា ពោលគឺការឆែកឆេរក្នុងបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ធ្វើឡើងគ្រប់ទីកន្លែងក្នុងករណីមានសម្រែកឲ្យជួយពីខាងក្នុងទីកន្លែង ឬក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងម៉ោងដែលបើចំហដល់សាធារណជន និងនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ករណីនេះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញាទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ផ្ទុយទៅវិញ មានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះដែលអាចធ្វើការឆែកឆេរក្នុងការិយាល័យមេធាវីបាន ហើយនៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី ពីព្រោះនៅក្នុងការិយាល័យមេធាវីមានការសម្ងាត់របស់កូនក្តីជាច្រើន គួរ

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ១០៦។
[55] ប្រសាសន៍ ឯ.ឧ ហ៊ី សោភា ក្នុងឪកាសឧទ្ទេសនាមស្តីពីសិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌។

បញ្ជាក់ដែរថាមេធាវីត្រូវរក្សាការសង្ងាត់ជូនអតិថជន ឬកូនក្តីរបស់ខ្លួនដោយគោរពលក្ខន្តិកៈមេធាវី មួយវិញទៀត មន្ត្រីនគរបាលយុត្តិធម៌មិអាចបើកប្រតិបត្តិការក្នុងក្របខណ្ឌការស៊ើបអង្កេតបទល្មើសជាក់ស្តែងនៅក្នុងអាគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ តែចំពោះមុខព្រះរាជអាជ្ញាដែលធានារ៉ាប់រងកុំឲ្យការឆែកឆេរនេះប៉ះពាល់ដល់ការប្រកបដោយសេរីនៅមុខរបរអ្នកសារព័ត៌មាន និង ធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ[56]។

គួរឲ្យកត់សម្គាល់ផងដែរថា ការឆែកឆេរក្នុងករណី ការស៊ើបអង្កេតជាក់ស្តែង ត្រឹមតែមានការអនុញ្ញាតដោយផ្ទាល់មាត់ពីព្រះរាជអាជ្ញា ឬករណីខ្លះត្រូវចូលរួមដោយផ្ទាល់ពីព្រះរាជអាជ្ញា និងភាគីពាក់ព័ន្ធតែប៉ុណ្ណោះ ក៏ចំពោះការស៊ើបអង្កេតបឋមវិញត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់ទីកន្លែង ដោយលាយលក្ខណ៍អក្សរ ដែលសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ប្រសិនអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរទេនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសរសេរក្នុងកំណត់ថាអ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ ផ្ទុយមកវិញប្រសិនបើអ្នកកាន់កាប់ទីកន្លែងបដិសេធមិនឲ្យឆែកឆេរព្រះរាជអាជ្ញាត្រូវសុំទៅកាន់ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី។ ដើម្បីឲ្យប្រធានសាលាដំបូងធ្វើការពិចារណាថា គួរចេញឲ្យអនុញ្ញាឲ្យឆែកឆេរ ឬយ៉ាងណា ហើយព្រះរាជអាជ្ញាត្រូវដឹកនាំការឆែកឆេរដោយផ្ទាល់។ សូមបញ្ជាក់ផងដែរថា នៅបណ្តាប្រទេសមួយចំនួន ប្រសិនបើអ្នកកាន់កាប់ទីកន្លែងបដិសេធការឆែកឆេរ តុលាការត្រូវបើសវនាការដេញដោលក្រោមការចូលរួមពីអ្នកកាន់កាប់ទីកន្លែង និងព្រះរាជអាជ្ញាដែលចុះទៅឆែកឆេរនោះ។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ព្រះរាជអាជ្ញាត្រូវសុំការអនុញ្ញាតពីប្រធានតុលាការដំបូងដែលមានសមត្ថកិច្ចដែនដី ឬព្រះរាជអាជ្ញាត្រូវធ្វើការឆែកឆេរនៅចំពោះមុខសាក្សីពីរនាក់ ដែលសាក្សីមិនអាចជានគរបាលយុត្តិធម៌ ឬជាកងកម្លាំងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។

## ២.៤ បទប្បញ្ញត្តិស្តីពីមោឃភាពកិច្ចនីតិវិធី

ចំពោះលក្ខណៈដូចគ្នារវាងការមោឃៈភាពក្នុងការស៊ើបអង្កេត យើងបានធ្វើការប្រដូចគ្នារួចមកហើយ។ ប៉ុន្តែលក្ខណៈខុសគ្នាដែលស្តែងអំពីបទប្បញ្ញត្តិមោឃភាព រវាងការស៊ើបអង្កេតជាក់ស្តែង និងស៊ើបអង្កេតបឋមវិញ យើងសង្កេតឃើញថាមានភាពខុសគ្នាច្រើន ពោលគឺក្នុងការស៊ើបអង្កេតជាក់ស្តែងមានប្បញ្ញត្តិស្តីពីមោឃភាពជាច្រើនដូចដែលមានចែង ក្នុងជំពូកទី១ ស្តីពីការស៊ើបអង្កេតជាក់ស្តែង។ លក្ខណៈខុសគ្នានោះ គឺការស៊ើបអង្កេតជាក់ស្តែង នគរបាលយុត្តិធម៌ត្រូវគោរព

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា ៩១។

ឲ្យបានម៉ត់ចត់ ដែលមានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនគោរពនូវបទប្បញ្ញត្តិនេះទេ នោះនឹងនាំឲ្យមានមោឃភាពកិច្ចនីតិវិធី ការមោឃៈភាពចំពោះការស៊ើបអង្កេតជាក់ស្តែងនូវវិធានការស្រាវជ្រាវលើកិច្ចឆែកឆេរ ដែលមានចែងក្នុងចំណុចទី២ ស្តីពីការឆែកឆេរនៃមាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំណែកឯការឆែកឆេរចំពោះករណីស៊ើបអង្កេតបឋម ត្រូវបានមោឃភាពតាមបទប្បញ្ញត្តិមាត្រា ១១៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលលក្ខណៈនេះមានភាពផ្ទុយគ្នាទាំងស្រុង រវាងការស៊ើបអង្កេតបឋម និងស៊ើបអង្កេតជាក់ស្តែងនេះ។

# សេចក្តីសន្និដ្ឋាន

ជារួម នៅក្នុងការស៊ើបអង្កេតក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ មានគោលបំណងចម្បងស្វែងរកអោយឃើញពីបទល្មើសដែលជនល្មើសបានប្រព្រឹត្ត ហើយរៀបចំសំណុំរឿងដើម្បីធ្វើការចោទប្រកាន់នៅចំពោះមុខតុលាការ ដែលអំណាចនៃការចោតប្រកាន់នេះត្រូវបានរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ប្រគល់ជូនស្ថាប័នងអយ្យការ[57]។ ដើម្បីចោទប្រកាន់អំពើមួយដែលចាត់ជាបទល្មើសស្ថាប័នងអយ្យការត្រូវដឹកនាំសម្រប់សម្រួលមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការស៊ើបអង្កេតក្រោមរូបភាពការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម។ ប្រសិនបើប្រៀបធៀបចំពោះការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម យើងឃើញមានចំណុចដូចគ្នា និងចំណុចខុសគ្នាគួរឲ្យកត់សម្គាល់ក្នុងការស៊ើបអង្កេតទាំងពីនេះ ប៉ុន្តែ ក្នុងការអនុវត្តន៍មានភាពស្មុំស្មាញមួយចំនួនដែលកើតឡើងមកពីការបែងចែងគ្នាមិនដាច់រវាងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមរបស់អ្នកមានសិទ្ធិអំណាចក្នុងការអនុវត្ត ដូចជាមន្ត្រីនគរបាលយុត្តិធម៌ និង ព្រះរាជអាជ្ញាជាអាទិ៍។ ហេតុនេះ ចំពោះការប្រៀបធៀបរវាងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមគឺដើរតួនាទីយ៉ាងសំខាន់ដើម្បីសម្របសម្រួលដល់បេសកម្មក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និង កិច្ចស្រាវជ្រាវរបស់ព្រះរាជអាជ្ញា។ យ៉ាងណាមិញ លក្ខណៈដូចគ្នានោះគឺបុគ្គលដែលអនុវត្តកិច្ចនីតិវិធី និង នីតិវិធីក្នុងការស៊ើបអង្កេត ព្រមទាំងចំណុចដូចគ្នាក្នុងបញ្ញត្តិមោឃៈភាព ជាមួយនឹងភាពដូចគ្នានៅក្នុងលក្ខណៈប្រគល់វត្ថុចាប់យកជាអាទិ៍។ ចំណែកឯ លក្ខណៈខុសគ្នានោះគឺអត្ថន័យនៃការស៊ើបអង្កេតជាក់ស្តែងនឹង ការស៊ើបអង្កេតបឋម ព្រមទាំងថិរវេលាក្នុងការឆែកឆេរ វិធានការណ៍ក្នុងការឆែកឆេរ និង បទប្បញ្ញត្តិស្តីពីការមោឃៈភាពនៃការស៊ើបអង្កេតបទល្មើសទាំងពីរ។

ហេតុនេះហើយ ធ្វើឲ្យយើងងាយស្រួលក្នុងការបែងចែកគ្នារវាងការស៊ើបអង្កេតជាក់ស្តែង និង ការស៊ើបអង្កេតបឋម ដើម្បីកុំឲ្យមានការមោឃៈភាពកិច្ចដែលបានបំពេញរួចហើយ និងមិនការបំពាន់សិទ្ធិពលរដ្ឋដោយមិនត្រឹមត្រូវនាពេលបំពេញបេសកម្ម ក្នុងការស្រាវជ្រាវស្វែងរកបទល្មើសព្រមទាំងបំពេញភារកិច្ចគោរពតាមគតិចច្បាប់ផងដែរ។

[57] មាត្រា១៣១ រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

# អនុសាសន៍

ដើម្បីចូលរួមចំណែកធ្វើឲ្យសារណារបស់ខ្ញុំ អាចយកទៅអនុវត្តន៍បាននៅក្នុងវិស័យយុត្តិធម៌នៃអំណាចតុលាការ ខ្ញុំសូមបញ្ចេញនូវមតិយោបល់មួយចំនួនជាការរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យយុត្តិធម៌នៃព្រះរាជាចក្រកម្ពុជាកាន់តែរីកចម្រើន និងគោរពបាននូវសិទ្ធិមនុស្ស ព្រមទាំងការពារឲ្យបាននូវការរំលោភបំពាន់ទៅលើពលរដ្ឋដោយមិនត្រឹមត្រូវដោយប្រការណាមួយ។ ខ្ញុំសូមផ្តល់នូវអនុសាសន៍ដល់ប្រជាពលរដ្ឋគ្រប់រូប សូមមេត្តាជួយសហការណ៍សមត្ថកិច្ចនគរបាលយុត្តិធម៌ និងសមត្ថកិច្ចផ្សេងទៀតដែលច្បាប់បានផ្តល់អំណាចឲ្យ នៅពេលមានបទល្មើសបានកើតឡើង ជាមួយមន្ត្រីនគរបាលយុត្តិធម៌ដូចជា មិនធ្វើការរារាំងដល់បេសកម្មរបស់សមត្ថកិច្ច តែផ្ទុយទៅវិញសូមពលរដ្ឋទាំងអស់គ្នាជួយរាយការណ៍ផ្តល់ទៅកាន់មន្ត្រីមានសមត្ថកិច្ច ដែលមានទីតាំងនៅជិតបំផុតពីបទល្មើសដែរអ្នកបានដឹង និងចូលរួមផ្តល់នូវភស្តុតាង ព្រមទាំងផ្តល់នូវពត៌មានដែលជាសញ្ញាណនៃបទល្មើស ឬ តម្រុយនៃបទល្មើស។ ចំពោះមន្ត្រីដែលមានសមត្ថកិច្ចវិញ សូមបំពេញតួនាទីរបស់ខ្លួនដោយប្រកាន់ភ្ជាប់នូវឆន្ទៈ ចំណេះដឹង និងក្រមសិលធម៌មន្ត្រីរាជការ ព្រមទាំងបំពេញបេសកម្មក្នុងការស៊ើបអង្កេតគោរពឲ្យបាននូវបទប្បញ្ញត្តិច្បាប់ដែលនៅជាធរមាន។ ដើម្បីធ្វើយ៉ាងណាជៀសវាងឲ្យបាននូវការរំលោភបំពាន់សិទ្ធិ និងផលប្រយោជន៍ ព្រមទាំងគោរពនូវសិទ្ធិសេរីភាព និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋនាពេលបើកប្រតិបត្តិការណ៍ស៊ើបអង្កេតទាំងស៊ើបអង្កេតបឋម និងការស៊ើបអង្កេតជាក់ស្តែង ក្នុងគោលបំណងប្រឆាំងដាច់ខាត់នូវការរំលោភបំពាន់សិទ្ធិមនុស្ស។ ជាចុងក្រោមខ្ញុំក៏សូមថ្លែងអំណរអរគុណដល់សមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដែលជានិច្ចជាកាលតែងតែការពារនិងទប់ស្កាត់នូវរាល់បទល្មើសដែលកើតឡើងនៅក្នុងសង្គមអស់ពីកម្លាំងកាយ ចិត្ត មិនថាយប់ ឬថ្ងៃមិនមានថ្ងៃឈប់សម្រាកឡើយ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។
- ឯកឧត្តម **ហ៊ី សោភា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ នៃ សាកលវិទ្យាល័យភូមិន្ទ និតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ នៃសាកលវិទ្យាល័យភូមិន្ទ និតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៥ - ២០១៦។
- និស្សិត វ៉ាត វិសិដ្ឋ, សារណាបញ្ចប់ការសិក្សា ស្ដីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌,ឆ្នាំ ២០១៥។
- សៀវភៅនីតិវីធីព្រហ្មទណ្ឌសម្រាប់នគរបាលយុត្តិធម៌។
- គេហទំព័រ www.lorkrem.com.kh
- ឯកសារសម្រាប់ផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ កើត រិទ្ធិ។
- ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌នៅឆ្នាំ២០០៨ ក្នុងកម្មវិធីផ្សព្វផ្សាយនីតិវិធីព្រហ្មទណ្ឌ ស្ដីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ទូរទស្សន៍ទទក។